CEDAC

# កសិករ និង ធម្មជាតិ

# Farmer and Nature

កម្រងសៀវភៅសម្រាប់អភិវឌ្ឍន៍កសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា

លេខ ៣ ខែសីហា ឆ្នាំ ២០០៤ | Nº 3, August 2004

## របៀបចិញ្ចឹមត្រីធម្មជាតិ



រៀបរៀងដោយៈ រាជ សុភាព

សេដាក, សីហា ២០០៤

**របៀបទាក់ទាញត្រីធម្មជាតិ**

**និពន្ធដោយ : រាជ សុភាព**

បោះពុម្ពលើកទី ១ នៅឆ្នាំ ២០០៤ ចំនួន ២០០០ ច្បាប់

បោះពុម្ពដោយ : រោងពុម្ពឥន្ទ្រីយ៍មាស

© សេដាក / CEDAC 2004

F4

# សេចក្តីថ្លែងអំណរគុណ

សៀវភៅស្តីអំពី "**របៀបទាក់ទាញត្រីធម្មជាតិ**" បានកើតឡើងជារូបរាងដោយឈរលើមូលដ្ឋាននៃការចុះសិក្សា និងបទពិសោធន៍ការទាក់ទាញត្រីធម្មជាតិរបស់កសិករកន្លងមកនៅខេត្តតាកែវ ព្រៃវែង និង ស្វាយរៀង។ ខ្ញុំចងក្រងជាសៀវភៅនេះ ក្នុងគោលបំណងដើម្បីជួយបំភ្លឺបន្ថែម នូវបច្ចេកទេសទាក់ទាញត្រីធម្មជាតិដល់កសិករមួយចំនួនដែលមិនទាន់ទទួលបច្ចេកទេសបានទូលំទូលាយ និងជួយផ្តល់យោបល់បន្ថែមដែលជាមូលដ្ឋានគ្រឹះក្នុងការទាក់ទាញត្រីធម្មជាតិរបស់ខ្លួនអោយបានទទួលផលខ្ពស់ជាងមុន។ ខ្ញុំព្យាយាមធ្វើយ៉ាងណាអោយសៀវភៅនេះមានលក្ខណៈសាមញ្ញ ដើម្បីអោយកសិករងាយយល់ និងអាចអនុវត្តបានក្នុងការទាក់ទាញត្រីធម្មជាតិ។

ខ្ញុំសូមថ្លែងអំណរគុណដល់កសិករដែលមានបទពិសោធន៍ក្នុងការទាក់ទាញត្រីធម្មជាតិកន្លងមកបានចូលរួមផ្តល់យោបល់ និងបទពិសោធន៍ ដូចជា កសិករ ពោជ រ៉ុន ហៀម មន់ អ៊ុង ស៊ីឡេង មៀវ វន់ នេទ ប៉ាក់ឡាយ សំបូរ ញូង មួង គង់ មឿង ហាម ត្រឹក កឺ សុងអេង និង ជា តិច (រស់នៅខេត្តព្រៃវែង) កសិករ ជា ថនកា ប៉ាក ឃិន សម្បត្តិ មុំ សារុន កែវ ថូ ណុប ណាង គង់ មឿន និង យុន ធី (រស់នៅខេត្ត តាកែវ) និង កសិករ រាជ ឆាន គីម សាវ៉ាន មាស ឡូ (រស់នៅខេត្តស្វាយរៀង)។

ទន្ទឹមនឹងនេះ ខ្ញុំក៏សូមថ្លែងអំណរគុណដល់បុគ្គលិកសេដាកទាំងអស់ដែលបានចូលរួមចំណែកផ្តល់យោបល់ជាពិសេសបុគ្គលិកមូលដ្ឋាន ដូចជា ម៉ា វាសនា ឃីម សុខសុភាស់ ហួត ស៊ីណាត អ្នកស្រី ម៉ី សុខជា កញ្ញា ម៉ុក ចិន្តា ស៊ិន អង្គារសាធ និង សាស្ត្រាចារ្យមហាវិទ្យាល័យជលផលនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និងអ្នកឯកទេសវារីវប្បកម្មនៃនាយកដ្ឋានជលផល។

ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ បណ្ឌិត យ៉ង សាំងកុមារ នាយកប្រតិបត្តិអង្គការសេដាក អ្នកស្រី ពាន សុខា មាស និមល និង លោក ឃីម សុផាណ្ណា ដែលបានចូលរួមចំណែកក្នុងការជួយនិពន្ធ កែលំអ និងជំរុញអោយសៀវភៅនេះចេញជារូបរាងឡើងសំរាប់កសិករ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអង្គការអុកស្វាមអាមេរិក **(Oxfam America)** ដែលបានឧបត្ថម្ភថវិកាក្នុងការផលិតសៀវភៅនេះ ។

ខ្ញុំយល់ថា សៀវភៅនេះមានចំណុចខ្វះខាតជាច្រើនទាំងខ្លឹមសារ និង រូបភាព។ ខ្ញុំសប្បាយរីករាយនូវការជួយកែលំអពីសំណាក់អ្នកអាន និងអ្នកអនុវត្តផ្ទាល់ ឬអ្នកមានចំណាប់អារម្មណ៍ផ្សេងៗ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទុកជាមុន ចំពោះការចូលរួមចំណែកដ៏មានតំលៃនេះ។

**រាជ សុភាព**

អ្នកនិពន្ធ

# មាតិកាអត្ថបទ

សេចក្តីថ្លែងអំណរគុណ ទំព័រ

១.សេចក្តីផ្តើម ..... ១

២. សារៈសំខាន់នៃការទាក់ទាញត្រីធម្មជាតិ ..... ២

៣. ចរិតរស់នៅ និងលក្ខណៈបន្សាំជីវិតប្រភេទត្រីមួយចំនួន..... ៥

៣.១. ត្រីក្រាញ់..... ៥

៣.២. ត្រីដីរ ..... ៦

៣.៣. ត្រីអណ្តែង ..... ៨

៣.៤. ត្រីផ្ទក់ ឬ ត្រីរស់ ..... ៩

៣.៥. ត្រីកន្ធរ ..... ១១

៤. គោលការណ៍ និងរបៀបទាក់ទាញត្រីធម្មជាតិ ..... ១៤

៤.១. ធនធាន និងកត្តាជាមូលដ្ឋានក្នុងការទាក់ទាញត្រីធម្មជាតិ ..... ១៤

៤.២ ការរៀបចំកន្លែងទាក់ទាញត្រីធម្មជាតិ ..... ១៤

៤.៣. ការគ្រប់គ្រងត្រីមេពូជ..... ២២

៤.៤. ការផ្តល់ចំណីបន្ថែម ..... ២៨

៤.៥. ការថែទាំ និងការពារត្រី..... ៣១

៤.៦. ការប្រមូលផលត្រី..... ៣៣

៤.៧. ការរក្សាទុកមេពូជត្រីបំរុង ..... ៣៤

៤.៨. វិធីការពារ និងព្យាបាលជំងឺ..... ៣៥

៥. បទពិសោធន៍សំខាន់ៗរបស់កសិករក្នុងការទាក់ទាញត្រីធម្មជាតិ..... ៣៦

៦. ការសរុបនូវចំនុចសំខាន់ៗក្នុងការទាក់ទាញត្រីធម្មជាតិបានផលខ្ពស់ ..... ៤១

ឧបសម្ព័ន្ធ

ឯកសារយោង

## បញ្ជីរូបភាព

ទំព័រ


រូបភាព ១ : ការប្រើឧបករណ៍នេសាទរារាំងដល់ការធ្វើចរាចរ និងរកកន្លែងពងកូន ..................... ៣
រូបភាព ២ : សកម្មភាពត្រីរកស៊ីសត្វល្អិតក្នុងស្រែ..................................................... ៣
រូបភាព ៣ : សត្វល្អិតជាចំណីត្រីដែលរស់នៅក្នុងទឹក ............................................ ៤
រូបភាព ៤ : ត្រីក្រាញ់ធ្វើសំបុកកន្លែងមានស្មៅដុះ................................................... ៦
រូបភាព ៥ : ដាក់បន្ទះឥដ្ឋអោយត្រីដីរធ្វើសំបុកពង ................................................ ៧
រូបភាព ៦ : ត្រីអណ្តែងរៀបចំធ្វើសំបុកពង ........................................................ ៨
រូបភាព ៧ : ត្រីផ្ទក់រៀបចំធ្វើសំបុកពង .............................................................. ១០
រូបភាព ៨ : ត្រីកន្ធររៀបចំធ្វើសំបុកពង............................................................. ១២
រូបភាព ៩ : ស្រះត្រីកន្ធរពងតាមធម្មជាតិ (រុក្ខជាតិដុះសំរាប់ធ្វើសំបុក) ............................ ១៣
រូបភាព ១០ : ធនធាន និងកត្តាជាមូលដ្ឋានក្នុងការទាក់ទាញត្រីធម្មជាតិ............................ ១៤
រូបភាព ១១ : គំនូសកាត់ទទឹងស្រះ (មើលពីចំហៀងស្រះ) ........................................ ១៥
រូបភាព ១២ : ការរៀបចំបៀវតាមអូរ (នៅដើមរដូវវស្សា) ........................................ ១៥
រូបភាព ១៣: រូបកាត់ទទឹងប្រឡាយ ( មើលពីចំហៀងប្រឡាយ) ................................ ១៦
រូបភាព ១៤ : ប្រព័ន្ធប្រឡាយក្នុងស្រែ ........................................................... ១៧
រូបភាព ១៥ : ការស្តារស្រះ (យកអាចម៍ដីតាមស្រទាប់) ........................................ ១៧
រូបភាព ១៦ : គំនូសច្រកផ្លូវត្រីចេញចូល (មើលពីលើ) ............................................ ១៨
រូបភាព ១៧ : បាចដីលាមកសត្វទ្រាប់បាតប្រឡាយ.................................................. ១៩
រូបភាព ១៨ : បាចកំបោរសរួចហាលថ្ងៃបាតស្រះ .................................................. ២០
រូបភាព ១៩ : ជំរកបាតស្រះ (គល់ឈើ) .......................................................... ២១
រូបភាព ២០ : ជំរកលើផ្ទៃទឹក (កំប្លោក កញ្ឆែត និងត្រកួន) នៅចំកណ្តាលស្រះ ........................ ២២
រូបភាព ២១ : មេពូជត្រីកន្ធរ ( រូបលើត្រីឈ្មោល និងក្រោមត្រីញី) ................................ ២៣
រូបភាព ២២ : មេពូជត្រីផ្ទក់ (រូបលើត្រីឈ្មោល និងក្រោមត្រីញី)................................. ២៤
រូបភាព ២៣: មេពូជត្រីក្រាញ់ (រូបខាងលើត្រីឈ្មោល និងក្រោមត្រីញី) .......................... ២៥
រូបភាព ២៤ : ត្រីអណ្តែង (រូបលើត្រីអណ្តែងទន់ និងក្រោមត្រីអណ្តែងរឹង)............................ ២៦
រូបភាព ២៥ : មេពូជត្រីដីរ (រូបខាងលើត្រីឈ្មោល និងក្រោមត្រីញី) ............................. ២៧
រូបភាព ២៦ : កូនសត្វជាចំណីត្រី ................................................................ ២៨

រូបភាព ២៧ : ធាតុផ្សំជាចំណីត្រី ( រុក្ខជាតិបៃតង និង កន្ទក់ ចុងអង្ករ ពោត....) ........................ ២៩
រូបភាព ២៨ : ការផ្សំចំណីអោយត្រីស៊ី ( កន្ទក់ ចុងអង្ករ ត្រកួន ដើមចេក...) ........................... ២៩
រូបភាព ២៩ : ស៊ុមដាក់ចំណីត្រីបន្លែស្រស់ ( ចកបាយទា ស្លែ ត្រកួន ស្លឹកដំឡូងជ្វា) ............. ៣០
រូបភាព ៣០ : ពិនិត្យចំណីដែលត្រូវផ្តល់បន្ថែម និងចំនួនត្រី ............................................. ៣០
រូបភាព ៣១ : ដាក់ពន្លឺចង្កៀងទាក់ទាញកូនសត្វល្អិត១ជាចំណីត្រី ......................................... ៣១
រូបភាព ៣២ : ចិញ្ច្រាំបន្លែស្រស់អោយត្រីស៊ី ........................................................................ ៣២
រូបភាព ៣៣ : ស៊ុមឈើក្រាលកៅស៊ូសំរាប់ស្តុកត្រីមេពូជពេលប្រមូលផល ( ទុកលែងចូលស្រះវិញ) .... ៣៣
រូបភាព ៣៤ : ថ្លុករក្សាទុកត្រីមេពូជនៅក្បែរអណ្តូងទឹក ( ទុកពូជឆ្នាំបន្ត) .............................. ៣៤
រូបភាព ៣៥ : ការលែងត្រីមេពូជ ( នៅដើមរដូវវស្សា) ...................................................... ៣៤

## បញ្ជីតារាង

ទំព័រ

តារាង ១ : ការកត់ត្រាលើមុខចំណាយផ្សេង១......................................................................៤២
តារាង ២ : ការកត់ត្រាការប្រមូលផលត្រី..............................................................................៤២

## កំណត់សំគាល់:

| | | |
|---|---|---|
| ម | : | អក្សរសរសេរកាត់ អានថា *ម៉ែត្រ* |
| ស.ម | : | អក្សរសរសេរកាត់ អានថា *សង្ទីម៉ែត្រ* |
| គ.ក្រ | : | អក្សរសរសេរកាត់ អានថា *គីឡូក្រាម* |
| ម$^{២}$ | : | អក្សរសរសេរកាត់ អានថា *ម៉ែត្រក្រឡា ឬ ម៉ែត្រការេ ( ១ ម៉ែត្របួនជ្រុង)* |
| ល.រ | : | អក្សរសរសេរកាត់ អានថា *លេខរៀង* |

## ខ្នាតដែលកសិករនិយាយច្រើ:

| | | |
|---|---|---|
| ១ លី = ១ មីលីម៉ែត្រ | ១ ហ៊ុន = ១ សង្ទីម៉ែត្រ | ១ តឹក = ១០ សង្ទីម៉ែត្រ |
| ១ ខាំ = ១០០ ក្រាម | ១០០ សង្ទីម៉ែត្រ = ១ ម៉ែត្រ | ១០០០ ក្រាម = ១ គីឡូក្រាម |

## ពន្យល់ន័យ:

- *ម៉ែត្រការេ :* មួយម៉ែត្របួនជ្រុង
- *ប្លង់តុង :* គឺ ជាពពួកសត្វ ឬ រុក្ខជាតិល្អិតៗដែលរស់នៅក្នុងទឹក ។
- *ប្លង់តុងសត្វ-ប្លង់តុងរុក្ខជាតិ ( ឬ ចំណីធម្មជាតិ) :* វាកើតឡើងក្រោយពេលដាក់ជីលាមកសត្វ - រុក្ខជាតិ និងបញ្ចូលទឹក ( រយះពេលពី ៥ - ១០ថ្ងៃ) ។
- *កំបោរសមានគុណភាព* : គឺប្រភេទកំបោរដែលរាយ( ផុស) ហើយដាក់ចូលក្នុងទឹកវាមានប្រតិកម្ម ( ពុះ) ។
- *ចំណីកែច្នៃ :* ជាចំណីដែលផ្សំពីធាតុមួយចំនួនចូលគ្នា ដូចជា កន្ទក់, ម្សៅពោត, ចុងអង្ករ, ម្សៅជំឡូង ។ល ។
- *ស៊ីចំណីចំរុះ :* ស៊ីសាច់ រុក្ខជាតិ កាកសំណល់ផ្ទះបាយ ចំណីកែច្នៃ លាមកសត្វជាអាហារ ។
- *ស្រះថ្មី :* ស្រះទើបនឹងជីករួច មិនទាន់ស្តុកទឹកបានមួយរដូវវស្សា ។
- *ហាលបាតស្រះ :* ពង្រឹងទឹកអោយរីងពីបាតស្រះរួចបាចកំបោរស ហើយទុកអោយបាតស្រះស្ងួត ។
- *បាចកំបោរស ( កំបោរលាបរបងផ្ទះ ឬ ជញ្ជាំងផ្ទះ) :*

  បាចកំបោរក្រោយពេលពង្រឹងស្រះ ( ភក់នៅសើម) ។ បាចកំបោរនៅពេលថ្ងៃក្តៅ ( មេឃគ្មានភ្លៀង) ។
- *អាហារបំរុង :* ជាចំណីមានស្រាប់ក្នុងខ្លួនកូនត្រី ( អាហារនេះធ្វើអោយកូនត្រីអាចរស់បានពី ១- ២ថ្ងៃ) ។
- *ពណ៌ទឹកមានគុណភាព :* ទឹកមានគុណភាពមានពណ៌ត្រួយចេក ឬ ពណ៌សំបកសណ្តែកខៀវ ។
- *ចរាចរត្រី :* ការបំលាស់ទីកន្លែងមួយទៅកន្លែងមួយ ដើម្បីរកកន្លែងដែលមានសុវត្ថិភាព មានចំណី និងពងកូន ។
- *រៀបចំជំរកត្រី :* រួមមានជំរកបាត និង ជំរកលើផ្ទៃទឹក

# ១. សេចក្តីផ្តើម

ប្រជាជនខ្មែរភាគច្រើន ជាពិសេសអ្នកដែលរស់នៅតាមជនបទប្រកបរបរចិញ្ចឹមជីវិតពឹងផ្អែកលើវិស័យកសិកម្មទាំងស្រុងគឺ ស្រូវ និងត្រី ដើម្បីដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃ។

បច្ចុប្បន្ននេះ ជំរកមច្ឆាជាតិកំពុងប្រឈមមុខនឹងការគំរាមកំហែងពីមនុស្ស និងធម្មជាតិជារៀងរាល់ឆ្នាំ ដូចជា ភាពប្រែប្រួលនៃធម្មជាតិ ភាពរាំងស្ងួតអូសបន្លាយ ទឹកជំនន់ ការប្រើឧបករណ៍នេសាទកាន់តែទំនើប (ឆក់ ស្បៃមុង អួនក្រឡាល្អិត ម៉ាស៊ីនបូម...) ការកាប់ព្រៃលិចទឹកដែលជាជំរកត្រីពងកូន ការប្រើថ្នាំពុល និងជីគីមី ធ្វើអោយពុលដល់មច្ឆាជាតិ។

ដើម្បីចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាខាងលើនេះ ខ្ញុំបានប្រមូលផ្តុំនូវបច្ចេកទេស បទពិសោធន៍ និងការដកស្រង់បទពិសោធន៍ពីកសិករដែលមានទំលាប់រក្សាទុកពូជត្រីធម្មជាតិមកចងក្រងជាសៀវភៅនេះ មានចំណងជើងថា "**របៀបទាក់ទាញត្រីធម្មជាតិ**"។

សៀវភៅនេះ អាចនឹងជួយអោយកសិករយល់ពីការទាក់ទាញត្រីធម្មជាតិដោយបង្កើតនូវជំរកត្រី និងទុកពូជត្រីក្នុងស្រះតាមគ្រួសារ។ មិនតែប៉ុណ្ណោះវាក៏ជួយបំផុសគំនិតដល់កសិករជួយថែរក្សាមច្ឆាជាតិតាមរយៈការផ្តល់បច្ចេកទេស របៀបរៀបចំជំរកត្រី ថែរក្សាទុកត្រីមេពូជតាមគ្រួសារ វត្តអារាម សហគមន៍ និងការពារបរិស្ថានអោយបានល្អ។ ការណែនាំក្នុងសៀវភៅនេះគឺ ផ្តោតទៅលើរបៀបរៀបចំសាមញ្ញៗដែលកសិករខ្លះពុំសូវបានចាប់អារម្មណ៍ ដូចជា ការរៀបចំស្រះ ធ្វើជំរកអោយត្រីលាក់ខ្លួន ផ្តល់ចំណី ទុកពូជ អោយត្រីស្គាល់ជំរក និងដឹងពីចរិតរស់នៅរបស់ត្រី។

ខ្លឹមសារក្នុងសៀវភៅនេះ ជួយណែនាំបង្ហាញប្រាប់ពីមូលដ្ឋានគ្រឹះសំខាន់ៗក្នុងការទាក់ទាញ និងអភិរក្សត្រីធម្មជាតិ និងបំភ្លឺផ្លូវដែលអ្នកបានជួបប្រទះក្នុងការថែរក្សាត្រីធម្មជាតិហើយអាចកែនូវចំនុចដែលខ្វះខាតណាមួយ ដើម្បីអោយផលត្រីកើនខ្ពស់ជាងមុន។

## ២. សារៈសំខាន់នៃការទាក់ទាញត្រីធម្មជាតិ

តាមទំនៀមទំលាប់ កសិករភាគច្រើនជីកស្រះ ឬ ប្រឡាយយកអាចម៍ដីដាក់ភូមិ និងលើកធ្វើសួនដំណាំបន្លែ ស្រះស្តុកទឹកសំរាប់ប្រើប្រាស់ និងនៅចុងរដូវវស្សាគេប្រមូលផលត្រីធម្មជាតិបានពីស្រះថែមទៀតផង។ ក្រោយមកដោយសារមានការគំរាមកំហែងពីមនុស្ស និងធម្មជាតិខ្លះ បានធ្វើអោយបរិមាណត្រីថយចុះ។ ឥឡូវនេះជំរុញអោយកសិករគិតដល់របៀបទាក់ទាញត្រីធម្មជាតិដូចជា រៀបចំស្រះ ធ្វើជំរក ផ្តល់ចំណី ទុកពូជត្រី និងបង្កើនការគ្រប់គ្រងបរិស្ថានល្អដល់ត្រី ដើម្បីអោយត្រីមានជំរករស់នៅ និងបង្កើតកូនចៅបន្ត។

**ចរាចរត្រីធម្មជាតិ (ត្រីបំលាស់ជំរក)**

▶ ដើមឆ្នាំរដូវវស្សាមានភ្លៀងធ្លាក់ (ខែពិសាខ) ត្រីចាប់ផ្តើមធ្វើចរាចរចេញពីទីជំរកចាស់ (បឹង ស្ទឹង ទន្លេ ព្រៃក ស្រះវត្ត) ទៅរកត្រពាំង ប្រឡាយ និងវាលទំនាបព្រៃលិចទឹក ដើម្បីស្វែងរកចំណីថ្មី និងទីកន្លែងពងកូនបន្ត។

**វាលស្រែ**



**ជំរកត្រី**

▶ នៅចុងរដូវវស្សា (ខែ អស្សុជ - កត្តិក) ទឹកនៅតាមវាលស្រែ ត្រពាំង ប្រឡាយ ស្រកជាបណ្តើរៗ ត្រីចាប់ផ្តើមបំលាស់ទីពីវាលស្រែមករស់នៅកន្លែងទឹកចាស់ដែលជ្រៅជាង ដូចជា ស្រះ បឹង ស្ទឹង ទន្លេ ព្រៃក អូរ។

ដូចនេះយើងត្រូវរៀបចំស្តារ សំអាតបាតស្រះ រៀបចំធ្វើជំរកលើ ជំរកបាត បើកច្រកផ្លូវទឹកអោយត្រីចេញចូល និងផ្តល់ចំណី ដើម្បីទាក់ទាញត្រីអោយចូលមក *ជំរកចាស់* (ស្រះ បៀវ ប្រឡាយ)។

រដូវត្រីចុះ (ការបំលាស់ទី) មានការខុសគ្នារវាងត្រីស្រែ និងត្រីទន្លេ ដូចខាងក្រោម:

- ☞ ត្រីស្រែ: ត្រីបំលាស់ទីមករស់នៅទឹកជ្រៅ (ជំរកចាស់)ចាប់ពី ខែអស្សុជ (តុលា) ដល់ខែមិគសិរ (វិច្ឆិកា)
- ☞ **ត្រីទន្លេ:** ត្រីចុះខ្លាំង ចំនួន ៣ថ្ងៃ គឺ ថ្ងៃ កោរ - ពេញបូណ៌មី - ១ រោច នៅខែមិគសិរ (ខែធ្នូ) និង នៅខែបុស្ស (ខែមករា)

ដូចនេះ ដើម្បីអោយត្រីនៅបានគង់វង្ស និងស្គាល់ជំរកយើងត្រូវរៀបចំនូវការងារមួយចំនួនដូចខាងក្រោម:

- ♦ សំអាតស្រះ, ធ្វើជំរកត្រី (លើ និងបាត) និងកាត់មែកឈើជុំវិញស្រះ (ស្លឹកឈើជ្រុះស្អុយទឹក) អោយផ្ទៃស្រលះទទួលបានពន្លឺព្រះអាទិត្យ
- ♦ រក្សាត្រីមេពូជក្នុងស្រុកបន្ថែម និងទុកពូជត្រីក្រោយពេលប្រមូលផល



**រូបភាព ១ : ការប្រើឧបករណ៍នេសាទរារាំងដល់ការធ្វើចរាចរ និងរកកន្លែងពងកូន**

- រៀបចំជំរកត្រីពីដើមឆ្នាំអោយត្រីស្គាល់ជំរក និងផ្តល់ចំណីទៀងទាត់
- បង្កលក្ខណៈអោយត្រីល្អិត១កើតច្រើន ដើម្បីទាក់ទាញត្រីធំបន្ថែម (ជាចំណីត្រីធំ)
- បើកច្រកផ្លូវទឹក ២ ឬ ៣ ច្រក ចូលស្រះ និងជីកប្រព័ន្ធប្រឡាយភ្ជាប់ជាមួយស្រះ ឬបៀរ
- ជៀសវាងការប្រើឧបករណ៍ឆក់ ថ្នាំពុល និង បូមផ្តាច់ពូជ
- រក្សាត្រីមេពូជដែលស្គាល់ជំរក

ត្រីធម្មជាតិរស់នៅក្នុងស្រែ ប្រឡាយ បៀរ ត្រពាំង មានសារៈប្រយោជន៍ ដូចជា វាស៊ីរុក្ខជាតិបួង់តុង សត្វបួង់តុង ដង្កូវ កណ្តូប ក្តាម កង្កែប ជន្លេន ផ្កាស្រូវជ្រុះ សត្វល្អិត១ រុក្ខជាតិមួយចំនួន ។ល។



**រូបភាព ២ : សកម្មភាពត្រីរកស៊ីសត្វល្អិតនៅក្នុងស្រែ**



រូបភាព ៣ : សត្វល្អិតជាចំណីត្រីដែលរស់នៅក្នុងទឹក (ប្លង់តុង)

## ៣. ចរិតរស់នៅ និងលក្ខណៈបន្តពូជនៃប្រភេទត្រីមួយចំនួន

### ៣.១. ត្រីក្រាញ់

#### ក. ចរិតរស់នៅ

ត្រីក្រាញ់រស់នៅតាមវាលស្រែ បឹងបួរ ប្រឡាយ ស្រះ បៀវ ត្រពាំង។ល។ ដែលមានជំរៅទឹកសមស្រប ពី ០,៨ - ១ ម។ ត្រីងាយផ្លាស់ទីកន្លែងនៅពេលមានភ្លៀង។ វាស៊ីចំណីចំរុះ ដូចជា កូនសត្វល្អិត១ កង្កែប ជន្លេន ស្រូវ កន្ទក់ គ្រាប់ធញ្ញជាតិ ជីលាមកសត្វ រុក្ខជាតិ។ល។

#### ខ. លក្ខណៈបន្តពូជ

ត្រីក្រាញ់ពេលពេញវ័យមានអាយុពី ៨ ទៅ ១០ ខែ។ តាមលក្ខខណ្ឌធម្មជាតិ ត្រីក្រាញ់ចាប់ផ្ដើមពងកូន នៅរដូវភ្លៀងដើមឆ្នាំ ប៉ុន្តែរដូវពងច្រើនបំផុតគឺ ពីខែឧសភា ដល់ខែកក្កដា និងដល់ខែកញ្ញា ទើបកន្សោមពង ថយចុះ។ ពេលពង វាធ្វើសំបុកតាមគុម្ពស្មៅ ឬ រុក្ខជាតិដុះក្នុងទឹក។ ត្រីញីទំងន់ពី ៣០ ទៅ ៧០ក្រាម ក្នុង ១ ក្បាល ហើយអាចមានពងពី ២.៥០០ ទៅ ១៥.០០០ គ្រាប់ពង។ រយៈពេលរវាងពងលើកទី ១ និងលើកទី ២ មានចន្លោះ ប្រហែលពី ២៥ ទៅ ៣០ ថ្ងៃ។ ត្រីក្រាញ់មានពងពណ៌លឿងជាំជាប់ជាតិខ្លាញ់ អណ្តែតលើផ្ទៃទឹក រហូតដល់ពេលពងញាស់។

#### គ. ចង្វាក់ញាស់ពង

ពេលពងបានពី ១៦ ទៅ ២២ ម៉ោង នៅលក្ខខណ្ឌសីតុណ្ហភាពទឹកពី ២៨ ទៅ ៣០ អង្សារសេ ទើបពង ញាស់ជាកូន។ កូនត្រីក្រាញ់ រស់ដោយប្រើអាហារបំរុងពី ២ ទៅ ៣ ថ្ងៃ។ ក្រោយអស់អាហារបំរុងកូនត្រីស៊ីអាហារ ខាងក្រៅ ដូចជា ពពួកបង្កងតុង គ្រាប់ធញ្ញជាតិ ដូចជា ផ្កាស្រូវ ស្មៅ កន្ទក់ បន្លែ និងស៊ីចំណីចំរុះ។ល។

✍ ចំនុចសំខាន់ៗ ដែលគេត្រូវយកចិត្តទុកដាក់ចំពោះត្រីក្រាញ់

- ត្រីក្រាញ់មានទំងន់ពី ៣០ ទៅ ៧០ ក្រាម ក្នុង ១ ក្បាល
- ក្នុងការចិញ្ចឹមយើងអាចលែងមេពូជ ពី ០,៥ គីឡូក្រាម (៤ - ៦ ក្បាល) ក្នុង ១ ម៉ែត្រការេស្រះ
- សមាមាត្រ ត្រីញីឈ្មោល គឺត្រីញី ១ក្បាល និង ត្រីឈ្មោល ២ ក្បាល
- វារស់នៅស្រទាប់លើ និងកណ្ដាលនៃផ្ទៃទឹក ចូលចិត្តចេញរកចំណីពេលថ្ងៃ
- ងាយរាលចេញពេលមានភ្លៀង
- វាស៊ីចំណី ដូចជា កូនសត្វល្អិត១ កូនត្រី កំពឹស ចង្ការ កន្ទក់ ចុងអង្ករ លាមកសត្វ ជីកំប៉ុស្ត ។ល។
- ស្រះត្រូវមានទំហំ ពី ១០០ ទៅ ៣០០ ម៉ែត្រការេ ជំរៅទឹកស្រះ ១ ទៅ ១,៥ ម៉ែត្រ
- ធ្វើជំរកលើផ្ទៃស្រះ ដាក់ចកជើងទា កំប្លោក ឬ កំពឹងពួយ ដើម្បីអោយត្រីធ្វើសំបុកពង
- ត្រីមានអាយុពី ៨ ទៅ ១០ ខែ ចាប់ផ្ដើមពងកូន ពងកូនជាលក្ខណៈធម្មជាតិ (ពងអណ្តែត)
- ត្រីពងនៅកន្លែងទឹករាក់ ជាពិសេសតាមជ្រលងទីសំណាប ឬ វាលស្រែ
- ធ្វើរបាំងព្រួល ឬ ស្បៃមុង ពីព្រោះត្រីប្រភេទនេះងាយរាលចេញទៅកន្លែងថ្មី។

## គ. ចង្វាក់លូតលាស់

ក្រោយពីទំលាក់ពងពី ២ ទៅ ៤ ថ្ងៃ និងសីតុណ្ហភាពទឹកពី ២៦ - ៣០ អង្សារសេ ពងត្រីដំរីចាប់ផ្តើមញាស់។ កូនត្រីអាយុបាន ៣ ទៅ ៤ ថ្ងៃ ចាប់ផ្តើមរកចំណីស៊ីខាងក្រៅ ហើយវាមានប្រវែងដងខ្លួនប្រហែល ៤ មីលីម៉ែត្រ។ ត្រីដំរីខុសពីប្រភេទត្រីផ្សេងៗទៀត គឺត្រីដំរីមានការលូតលាស់យឺតក្នុងដំណាក់កាល ទំងន់ក្រោម ១ ខាំ តែបើមានទំងន់លើសពី ១ ខាំ ឡើងទៅ វាមានការលូតលាស់លឿនបង្គួរ។ កូនត្រីដំរីជាប្រភេទសំងំចាំស៊ីចំណី គឺវាមិនចេញចាប់ចំណីដូចប្រភេទត្រីឯទៀតទេ។ ដូចនេះហើយទើបអត្រាកូនត្រីដំរីមានតិចបំផុត ជាហេតុធ្វើអោយប្រភេទត្រីដំរីគេនេសាទបានមានតិចតួច។

**ចំនុចសំខាន់ៗដែលគេគួរយកចិត្តទុកដាក់លើប្រភេទត្រីដំរី :**

- សំអាតស្រះ បាចកំបោរស ៣-៥ គីឡូក្រាម ក្នុងស្រះ ១០០ ម៉ែត្រការេ
- ដាក់លាមកគោ ឬ ក្របី ៣០ គីឡូក្រាម និងទន្រ្ទានខៃត្រ ២០ គីឡូក្រាម ក្នុងស្រះ ១០០ ម៉ែត្រការេ
- ទំហំស្រះ ពី ៨០ - ៥០០ ម៉ែត្រការេ ជំរៅ ២ ម៉ែត្រ
- ជាត្រីស៊ីចំណីស្រស់ (រស់) កូនសត្វរស់នៅក្នុងទឹក កូនត្រី កង្កែប ក្តាម ខ្យង កំពីស ត្រីចង្វារ ។ល។
- អាយុពី ៩ - ១២ ខែ ចាប់ផ្តើមពងកូន ជាប្រភេទត្រីពងតោងពងកូនតាមធម្មជាតិ
- ១ គីឡូក្រាមត្រីញី ពងបានពី ១៥០.០០០ - ២០០.០០០ គ្រាប់ពង
- ធ្វើជំរកបាតស្រះ ដាក់គល់ស្មាយ មែកអំពិលទឹក គល់ត្នោត ធ្វើជាកន្លែងត្រីលាក់ខ្លួន និងពងកូន
- ចំណីស្រស់ដូចជា សាច់ត្រីល្អិតៗ ពោះវៀនមាន់ ទា និងជ្រូក ហាន់តូចៗ
- គេអាចធ្វើសំបុកអោយត្រីពង ដោយដាក់បន្ទះឥដ្ឋពីរ (ឥដ្ឋកន្សែង) បញ្ឈរអោយបានមុំ ៤៥ ដឺក្រេ (រាងជាដំបូលផ្ទះ) ផុតពីបាតស្រះកំពស់ពី ២ ទៅ ៣ តឹក ។ ចំងាយពីសំបុកមួយ ទៅសំបុកមួយទៀត ពី ២-៣ ម៉ែត្រ។ កសិករគប្បីការពារការឆក់ និងផ្តល់ចំណីបន្ថែម ដូចជា កន្ទក់ ចុងអង្ករ អង្រ្កង កណ្តៀវ កាកសំណល់ផ្ទះបាយ និងជីកំប៉ុស្ត ដើម្បីអោយពពួកត្រីតូចៗមកចូល និងកកើតកូនចៅ ដែលជាចំណីត្រីដំរី។



**រូបភាព ៥ : ដាក់បន្ទះឥដ្ឋអោយត្រីធ្វើសំបុកពង**

### ៣.៣. ត្រីអណ្ដែង

#### ក. ជីវិតរស់នៅ

ត្រីអណ្ដែង ជាប្រភេទត្រីកាច (ស៊ីចំណីស្រស់) ដែលរស់នៅតាមវាលស្រែ បឹងបួរ ប្រឡាយ ស្រះ ត្រពាំង ព្រៃលិចទឹក។ល។ វាជាប្រភេទត្រីរកស៊ីនៅផ្ទៃស្រទាប់បាត ពីព្រោះវាមានព្រុយពុកមាត់ (សំរាប់ស្រង់ក្លិន) ងាយនឹងចាប់ចំណី។ ត្រីនេះមានចរិតចូលចិត្តឈ្មុលចូលភក់ ឬមមោកនៅបាតស្រះ។ វាអាចរស់ក្នុងទឹកល្អក់ និងអាចរស់នៅលើគោកបានមួយរយៈ។ ម្យ៉ាងទៀត កន្លែងដែលខ្វះអុកស៊ីហ្សែនវាក៏អាចរស់នៅបាន ១ រយៈពេលយូរបង្គួរដែរ។ វាអាចធន់បានសីតុណ្ហភាពទឹកពី ១៥ ទៅ ៣៥ អង្សារសេ ។ ត្រីអណ្ដែងទន់ សំបូរនៅកន្លែងណាមានមមោក ឬស្មៅត្រីប (ស្មៅទន់ៗ ដុះនៅកណ្ដាលបឹង) ចំណែកត្រីអណ្ដែងរឹងចូលចិត្តរស់នៅតាមវាលស្រែ។



**រូបភាព ៦ : ត្រីអណ្ដែងរៀបចំធ្វើសំបុកពង**

ត្រីអណ្ដែង ជាប្រភេទត្រីស៊ីចំណីចំរុះ ដូចជា កូនសត្វល្អិតៗ កំពឹស កូនត្រីតូចៗ កូនកង្កែប ក្អុក ខ្យង លាមកសត្វ កន្ទក់ ចុងអង្ករ កាកសំណល់ផ្ទះបាយ សំណល់ពីឡសត្តឃាដ ។ល។ ជំរៅទឹកដែលត្រីអណ្ដែងរស់នៅបានល្អគឺចាប់ពី ០,៥ ទៅ ១,៥ ម៉ែត្រ។

#### ខ. លក្ខណៈបន្តពូជ

ត្រីអណ្ដែងអាយុពី ១០ ទៅ ១២ ខែ ចាប់ផ្ដើមពងកូន។ នៅក្នុងលក្ខខណ្ឌធម្មជាតិសមស្រប ដូចជា សំបូរចំណី ទឹកល្អ អាកាសធាតុសមស្រប ត្រីអណ្ដែងអាចពងស្ទើរពេញ ១ ឆ្នាំ។ ប៉ុន្តែរដូវដែលត្រីពងច្រើនបំផុតពីខែឧសភា ដល់ខែកញ្ញា។ ត្រីអណ្ដែងពងនៅកន្លែងមានរូងរន្ធគល់ឈើ រំចេក គ្រោះ ស្មៅទឹក ឬឫស្សីព្រៃដុះនៅក្នុងទឹក។ វាពងនៅពេលព្រឹកព្រលឹមក្រោយពេលភ្លៀងធ្លាក់។ ក្រោយពងរួចត្រីអណ្ដែងឈ្មោលការពារ

សំបុកចំណែកត្រីញីនៅស្ងៀម ។ ពងត្រីអណ្តែងមានពណ៌លឿងតោងជាប់នឹងរុក្ខជាតិរហូតដល់ញាស់ ។ ត្រីញីទំងន់ ១ គីឡូក្រាម មានពងពី ៥០.០០០ ទៅ ៧០.០០០ គ្រាប់ ។ ត្រីពងរវាងលើកទី ១ និងលើកទី ២ ចន្លោះប្រហែលពី ៣០ ទៅ ៣៥ ថ្ងៃ ។ ត្រីអណ្តែងអាចពងបានពី ៤ ទៅ ៦ ដង ក្នុង ១ ឆ្នាំ ។

### គ. ចង្វាក់លូតលាស់

ក្រោយពេលទំលាក់ពងបានរយៈពេលពី ២៣ - ២៥ ម៉ោង ក្នុងលក្ខខណ្ឌសីតុណ្ហភាពទឹកពី ២៧ - ៣០ អង្សារសេ ពងត្រីញាស់ជាកូន ។ កូនត្រីដែលទើបនឹងញាស់រស់នៅផ្ទៃបាតផ្តុំគ្នា និងអាចរស់ដោយអាហារបំរុងពី ២ - ៣ ថ្ងៃ ។ កូនត្រីតូចៗស៊ីដូចជា ពពួកសត្វបួងតុងរស់នៅក្នុងទឹក សត្វងាប់រលួយក្នុងទឹក មមោកនៅបាតស្រះ ។ កូនត្រីធំបន្តិចស៊ីចំណីចំរុះ ដូចជា រុក្ខជាតិ កូនសត្វល្អិតៗ កង្កែប ជន្លេន កូនត្រីតូចៗ ក្តាម ខ្យង ។ ក្រៅពីនេះវាស៊ី កន្ទក់ ចុងអង្ករ បាយស្រោ សត្វស្អុយរលួយ កាកសំណល់ផ្ទះបាយ កាកសំណល់សត្តឃាដ ។ល ។ ត្រីអណ្តែងមានការលូតលាស់យឺត ។ ត្រីអណ្តែងមានទំងន់ជាមធ្យម ប្រមាណជា ៣ ខាំ ក្នុង ១ ក្បាល ។

✍ **ដើម្បីរក្សាត្រីអណ្តែងតាមបែបធម្មជាតិឱ្យបានច្រើនត្រូវអនុវត្តនូវចំណុចមួយចំនួនដូចខាងក្រោម:**

- ធ្វើជំរកនៅបាតស្រះ ដាក់គល់ឈើដើម្បីអោយត្រីធ្វើសំបុកពង
- ផ្តល់ចំណីដល់កូនត្រីតូចៗ ស៊ីអោយបានគ្រប់គ្រាន់ ដូចជា ពពួកសត្វបួងតុងរស់នៅក្នុងទឹកសត្វងាប់រលួយក្នុងទឹក និងមមោកនៅបាតស្រះ
- ធ្វើកន្លែងឱ្យត្រីពងនៅកន្លែងមានរន្ធរូងគល់ឈើ ដើមគ្រោះ ស្មៅទឹក ឬស្សីព្រៃនៅក្នុងទឹក ព្រោះពងរបស់វាតោងស្អិតនឹងរុក្ខជាតិ ។

## ៣.៤. ត្រីឆ្តោ ឬ ត្រីរ៉ស់

### ក. ទីជំរករស់នៅ

ត្រីផ្ទក់រស់នៅតាមស្ទឹង ទន្លេ អូរ បឹង វាលស្រែ ស្រះ ប្រឡាយ ត្រពាំង និងតំបន់ព្រៃលិចទឹក ។ ក្នុងធម្មជាតិត្រីផ្ទក់ ងាយបំលាស់ទីពីកន្លែងមួយទៅកន្លែងមួយដើម្បីរកចំណីស៊ី និងកន្លែងពងកូន ជាពិសេសពេលមានភ្លៀងម្តងៗ ។ បើនៅកន្លែងណាដែលមានសុវត្ថិភាព និងសំបូរចំណីវារស់នៅពេញមួយឆ្នាំ ។ ត្រីផ្ទក់ចូលចិត្តរស់នៅកន្លែងមានទឹកហូរតិចៗ និងកន្លែងដែលមានស្មៅ ឬរុក្ខជាតិដុះ ( កំពឹងពួយ កំប្លោក ព្រលិត រំចង់ ។ល ។ ) នៅតាមបឹង ស្រះ ប្រឡាយ ។ល ។ វាងាយលាក់ខ្លួនដើម្បីចាប់ចំណីស៊ីដូចជា កូនសត្វស្លាបតូចៗ ដង្កូវ ក្អុក កង្កែប ក្តាម ជន្លេន កូនត្រីតូចៗ ខ្យង ។ល ។ នៅលក្ខខណ្ឌធម្មជាតិ ត្រីផ្ទក់ចូលចិត្តរស់នៅសីតុណ្ហភាពទឹកពី ២០-៣០ អង្សារសេ និងធ្វើសំបុក ( កាច់សំបុក) ពងនៅកន្លែងមានស្មៅដុះមានម្លប់ត្រជាក់ ។ ត្រីញីការពារពងកូន បណ្តើរកូន រីឯត្រីឈ្មោលវិញ នៅឆ្ងាយពីត្រីញីជាអ្នកអោយសញ្ញាពេលមានសត្រូវមកដល់ ។ ជំរៅទឹកដែលត្រីផ្ទក់ចូលចិត្តរស់នៅចាប់ពី ៣ តឹក ឡើងទៅ ។



**រូបភាព ៧ ៖ ត្រីផ្ទក់រៀបចំធ្វើសំបុកពង**

**ខ. លក្ខណៈបន្តពូជ**

រដូវភ្លៀងធ្លាក់ដើមឆ្នាំ (ខែឧសភា) ត្រីផ្ទក់ចាប់ផ្ដើមចេញពីជំរក (បឹងបួរ ប្រឡាយ ព្រែក ទន្លេ ស្រះវត្ត) ទៅតាមវាលស្រែ ស្រះ ប្រឡាយ ដើម្បីរកចំណី និងកន្លែងពងកូន។ នៅចុងរដូវវស្សាខែតុលា និងខែវិច្ឆិកា (ខែអស្សុជ - កត្តិក) ត្រីផ្ទក់ផ្លាស់ទីត្រលប់មកកន្លែងដើមវិញ (ជំរកចាស់)។

ត្រីផ្ទក់ចាប់ផ្ដើមពងកូនលើកដំបូងនៅអាយុពី ១០ ទៅ ១២ ខែ ។ រដូវត្រីផ្ទក់ពងច្រើនបំផុតពីខែឧសភាដល់ខែកក្កដា។ នៅលក្ខខណ្ឌធម្មជាតិសមស្រប ដូចជា សំបូរចំណី មានទឹកគ្រប់គ្រាន់ មិនថារដូវប្រាំង ឬ វស្សាទេ គឺត្រីពងស្ទើរពេញមួយឆ្នាំ។ វាធ្វើសំបុកពង (កាច់សំបុក) នៅកន្លែងដែលមានរុក្ខជាតិដុះគ្របពីលើផ្ទៃទឹក និងកន្លែងស្ងៀមស្ងាត់។ ត្រីនេះពងពេលព្រឹកព្រលឹម ឬ ក្រោយមានភ្លៀងធ្លាក់ពី ២ - ៣ ថ្ងៃ។ ត្រីញីទំងន់ពី ៨ ខាំ ទៅ ១ គីឡូក្រាម ហើយត្រីមួយក្បាលអាចទំលាក់ពងបានពី ៨.០០០ ទៅ ១៥.០០០ គ្រាប់ និងអាចពងបាន ៥ ដង ក្នុង ១ ឆ្នាំ។ ចន្លោះពងលើកទី ១ និងលើកទី ២ ប្រហែលពី ២០ ទៅ ២៥ ថ្ងៃ។ ពងត្រីផ្ទក់ជាប្រភេទពងអណ្ដែតលើផ្ទៃទឹករហូតដល់ពេលញាស់ ។ ត្រីឈ្មោល និងញីការពារពងរហូតដល់ពេលញាស់ និងបណ្ដើរកូនជាហ្វូងដល់កូនត្រីចេះរកចំណីស៊ីដោយខ្លួនឯង។

**គ. ទង្វាក់លូតលាស់**

ពងត្រីផ្ទក់ពណ៌លឿង ជិតញាស់ពណ៌ក្រមៅ (ពណ៌ត្នោត)។ ក្រោយពីទំលាក់ពងបានពី ២០ ទៅ ២៦ ម៉ោង សីតុណ្ហភាពទឹកពី ២៨ ទៅ ៣០ អង្សារសេ គឺពងត្រីផ្ទក់ចាប់ផ្ដើមញាស់។ ពេលទើបនឹងញាស់កូនត្រីផ្ទក់អាចរស់ដោយអាហារបំរុងបានពី ៣ ទៅ ៤ ថ្ងៃ។ ក្រោយពេលញាស់កូនត្រីមានពណ៌ក្រហមបណ្ដើរគ្នាជាហ្វូង

និងមេឈប់បណ្ដើរក្រោយពីកូនមានអាយុពី ២៥ ទៅ ៣០ ថ្ងៃ ដល់ពេលនោះ ខ្លួនកូនត្រីពណ៌ខៀវស្រាល (ស្លែ) ដងខ្លួនប្រវែងពី ៤ ទៅ ៥ សង់ទីម៉ែត្រ។ ក្រោយពីអស់អាហារបំរុង វាស៊ីពពួកសត្វបួងតុង ដង្កូវទឹក ជន្លេន កូនត្រីតូចៗ (កំពីស ចង្វារ.....)។ ត្រីផ្ទក់ស៊ីចំណីស្រស់ (រស់) ដូចជា កូនសត្វល្អិតៗ កង្កែប ជន្លេន ក្អុក កូនត្រីតូចៗ ក្ដាម ខ្យង ។ល។

✍ **ចំនុចសំខាន់ៗដែលគួរយកចិត្តទុកដាក់លើប្រភេទត្រីផ្ទក់មានដូចខាងក្រោម:**

- ត្រីផ្ទក់រស់នៅស្រទាប់លើ និងស្រទាប់កណ្ដាលនៃផ្ទៃទឹក
- ត្រីផ្ទក់ចេញរកចំណីនៅពេលព្រឹកព្រលឹម ដល់ល្ងាចព្រលប់
- ត្រីផ្ទក់ចូលចិត្តស៊ីចំណីស្រស់ (រស់) ដូចជា កូនត្រី កង្កែប ក្ដាម ខ្យង កំពីស ត្រីចង្វារ ។ល។
- ត្រីនេះធ្វើសំបុកពង (កាច់សំបុក) ក្រោមគុម្ពស្មៅដែលដុះតាមមាត់បឹង ប្រឡាយ ស្រះ ។ល។
- ត្រីពងជាលក្ខណៈធម្មជាតិ ចេះការពារពង កូន និងបណ្ដើរកូនរកចំណីស៊ី
- ត្រីចេញពីជំរកពេលមានភ្លៀងដើមឆ្នាំ (ខែពិសាខ - ជេស្ឋ) និងចូលមកជំរកវិញ នៅចុងរដូវវស្សា (ខែអស្សុជ -កត្ដិក)
- អាយុពី ១០ - ១២ ខែ ចាប់ផ្ដើមពង និងកូន អាចពងបាន ៤ - ៥ ដងក្នុង ១ ឆ្នាំ
- ត្រីផ្ទក់ញីដែលមានទំងន់ ១ គីឡូក្រាមអាចពងបានពី ៨.០០០ ទៅ ១៥.០០០ គ្រាប់
- ជាប្រភេទត្រីពងអណ្ដែត ហើយក្រោយទំលាក់ពងពី ២០ - ២៦ ម៉ោង ពងញាស់ជាកូន
- ធ្វើជំរកលើនៃផ្ទៃទឹក អាចដាក់កំប្លោក កំពឹងពួយ ត្រកួន កញ្ឆែត ដើម្បីអោយវាធ្វើសំបុកពង
- ធ្វើជំរកបាតស្រះ ដោយដាក់គល់ស្វាយ មែកអំពិលទឹក គល់ត្នោត ធ្វើជាកន្លែងត្រីលាក់ខ្លួន
- បើកច្រកមាត់ស្រះ (រង្វះទឹក) ពី ២ ទៅ ៣ ច្រក ដើម្បីអោយត្រីចូលមករកជំរកវិញ
- បើមិនបានបន្សាំអោយត្រីស្គាល់ជំរក គឺត្រូវធ្វើរបាំងព្រួល ឬ សៃ្បរាំងការពារត្រីកុំឱ្យចេញពីស្រះ
- ដាក់ចំណីបន្ថែមជាប្រចាំ

## ៣.៥. ត្រីកន្ធរ

### ក. ទីរស់នៅ

ត្រីកន្ធររស់នៅតាមវាលស្រែ បឹងបួរ ប្រឡាយ ស្រះ ត្រពាំង ជំរករុក្ខជាតិលិចទឹកដែលមានរុក្ខជាតិស្អុយរលួយក្នុងទឹក។ នៅលក្ខខណ្ឌធម្មជាតិ ត្រីកន្ធរចូលចិត្តរស់នៅសីតុណ្ហភាពទឹកចន្លោះពី ២៥ - ៣០ អង្សាសេ និងពងកូន ល្អតលាស់នៅកន្លែងដែលមានទឹកសំបូរទៅដោយសារធាតុសរីរាង្គរលួយ (រុក្ខជាតិលិចរលួយក្នុងទឹក ដូចជា ស្មៅ ចក កំប្លោក ត្រកួន និងលាមកសត្វ) ។ ចំណីរបស់ត្រីកន្ធរដូចជា កាកសំណល់រលួយ

នៅបាតស្រះ ឬបូងតុង សារាយ ចកពងទឹក ចកបាយទា លាមកសត្វ កន្ទក់ ចុងអង្ករ កាកសំណល់ផ្ទះបាយ ។ ជំរៅទឹកដែលត្រីកន្ធរអាចរស់នៅបានចាប់ពី ៣ តឹក ទៅ ១ ម៉ែត្រ ។

**ខ. លក្ខណៈបន្តពូជ**

ត្រីកន្ធរចាប់ផ្តើមពងកូននៅរដូវភ្លៀងដើមឆ្នាំ ។ ប៉ុន្តែរដូវពងច្រើនបំផុតពីខែឧសភា ដល់ខែតុលា ។ វាពងនៅកន្លែងណាមានរុក្ខជាតិដុះក្នុងទឹក ដើម្បីងាយធ្វើសំបុកក្រោមស្មៅ ឬកំប្លោក ។ មុនពេលពង វាបញ្ចេញទឹកជាពពុះនៅលើផ្ទៃទឹកដើម្បីពង ។ មួយគីឡូក្រាមត្រីកន្ធរញីមានពងពី ១៥០.០០០ - ២០០.០០០ គ្រាប់ ឬអាចដល់ទៅ ៣០០.០០០ គ្រាប់ពង ។ ពងចន្លោះពេលពីលើកទី ១ ទៅលើកទី ២ ប្រហែលពី ២៥ ទៅ ៣០ ថ្ងៃ ។ ត្រីកន្ធរពងពី ៣ ទៅ ៤ ដង ក្នុងមួយឆ្នាំ ។ ពងត្រីកន្ធរមានពណ៌លឿងហើយមានជាប់ជាតិខ្លាញ់អណ្តែតត្រាៗលើផ្ទៃទឹក រហូតដល់ពេលញាស់ ។



**រូបភាព ៨ : ត្រីកន្ធររៀបចំធ្វើសំបុកពង**

**គ. ចង្វាក់ញាស់**

ក្រោយពេលទំលាក់ពងបានពី ២០ - ២៤ ម៉ោង នៅសីតុណ្ហភាពទឹកពី ២៨ - ៣០ អង្សាសេ ទើបពងញាស់ជាកូន ហើយកូនអណ្តែតនៅលើផ្ទៃទឹក ក្រោយមកទើបហែលទៅស្រទាប់ទឹកជ្រៅជាង ។ កូនត្រីកន្ធរ ដែលទើបនឹងញាស់រស់ដោយប្រើអាហារបំរុងរយៈពេលពី ២ - ៣ ថ្ងៃ ។ ក្រោយពីអស់អាហារបំរុងវាស៊ីប្លង់តុង ( រុក្ខជាតិសត្វតូចល្អិតៗ) និងស៊ីចំណីចំរុះ ជាពិសេសសារធាតុរលួយនៅបាតស្រះ ។ ត្រីកន្ធរឆាប់ពេញវ័យ ។ បន្ទាប់ពីមានអាយុចាប់ពី ៧ - ១០ ខែវាអាចចាប់ផ្តើមចូលរួមបន្តពូជ ( ពងកូន) ។

**ចំនុចសំខាន់ៗដែលគួរយកចិត្តទុកដាក់លើប្រភេទត្រីកន្ធរ :**

- រស់នៅស្រទាប់ផ្ទៃលើ កណ្តាល និងបាតនៃផ្ទៃទឹកវាស៊ីចំណីចំរុះ ពពួកសត្វ និងរុក្ខជាតិរលួយនៅបាតស្រះ
- វាស៊ីសារធាតុរលួយនៅបាតស្រះ កាកសំណល់ផ្ទះបាយ  កន្ទក់ ចកបាយទា រុក្ខជាតិរលួយលិចទឹក
- ធន់នឹងមជ្ឈដ្ឋានទឹកដែលមានអុកស៊ីហ្សែនទាប ( ខ្យល់តិចក្នុងទឹក)
- ងាយចិញ្ចឹម និងពងកូនច្រើន
- ចិញ្ចឹមបានក្នុងស្រះ ប្រឡាយ បៀវ ស្រែ ទំហំមានពី ៥០ - ១០០ ម $^{២}$ ជំរៅទឹក ១ – ១,៥ម
- ត្រីកន្ធរអាយុពី ៧ - ១០ ខែចាប់ផ្តើមពងកូន ហើយពងអណ្តែតលើផ្ទៃទឹកជាប់នឹងពពុះទឹក
- ស្រះត្រីកន្ធរត្រូវដាក់កំប្លោក ២ ភាគ ៣ នៃផ្ទៃស្រះ ដើម្បីអោយវាធ្វើសំបុកពង
- ចិញ្ចឹមមួយឆ្នាំបានទំងន់ ពី ១ ខាំ - ២ ខាំ ក្នុងមួយក្បាល ។



**រូបភាព ៩ : ស្រះត្រីកន្ធរបងតាមធម្មជាតិ (រុក្ខជាតិដុះសំរាប់ធ្វើសំបុក)**

## ៤. គោលការណ៍ និងរបៀបទាក់ទាញត្រីធម្មជាតិ

### ៤.១. ធនធាន និងកត្តាជាមូលដ្ឋានក្នុងការទាក់ទាញត្រីធម្មជាតិ

ការទាក់ទាញត្រីធម្មជាតិផ្អែកលើកត្តាមួយចំនួនដូចជា ការសំអាតស្រះ បឹង រៀបចំធ្វើជំរក រក្សាទុកត្រីមេពូជតាមត្រួសារ ស្រះរួម ស្រះវត្ត។ ក្រៅពីនេះត្រូវផ្គត់ផ្គង់ទឹក ផ្តល់ចំណី មានបទពិសោធន៍ មានបច្ចេកទេសការពារ និងថែទាំ។ ដូចនេះដើម្បីទទួលបានផលត្រីធម្មជាតិប្រសើរជាងមុន អ្នកគប្បីស្វែងយល់ចំនុចមួយចំនួនដូចខាងក្រោម :




**រូបភាព ១០ : ធនធាន និងកត្តាជាមូលដ្ឋានក្នុងការទាក់ទាញត្រីធម្មជាតិ**

### ៤.២. ការរៀបចំកន្លែងទាក់ទាញត្រីធម្មជាតិ

#### ក. ទីតាំងជីកស្រះ បឹង និងប្រឡាយ

ជ្រើសរើសទីកន្លែងជីកស្រះ បឹង និងប្រឡាយ ដូចខាងក្រោម:

- បើជីកក្បែរផ្ទះងាយស្រួលថែរក្សា និង គ្រប់គ្រង
- នៅតាមវាលទំនាបលិចទឹក និងច្រកផ្លូវត្រីចុះឡើង ( ផ្លូវទឹកហូរចុះ)
- នៅតាមបឹង ត្រពាំង អូរ ព្រែក និងវាលទំនាបលិចទឹក
- នៅឆ្ងាយពីដើមឈើធំៗ

## ខ. របៀបជីកស្រះ និង បៀវ

គប្បីជីកស្រះ ឬ បៀវ រាងជាចតុកោណកែង ឬ រាងជាការេ និងបាតស្រះជំរាលទៅរង្វះផ្លូវទឹកចេញចូលស្រះ ដើម្បីងាយអូសចាប់ត្រី និងពង្រីង។ ទំហំស្រះពី ១០០ - ៥០០ ម៉ែត្រការេ ឬ ១.០០០ ម៉ែត្រការេ និង ជំរៅពី ២ - ៣ ម៉ែត្រ។ ជញ្ជាំងស្រះមានជើងទេរ (មិនចោតចុះពេក) ។ កំពស់ទំនប់ស្រះពី ០,៤ - ០,៦ ម៉ែត្រ ។ បាតស្រះរាបស្មើ តែជំរាលងាកមករង្វះរបញ្ចេញបញ្ចូលទឹក។




រូបភាព ១១ : កំនូសកាត់ទទឹងស្រះ (មើលពីចំហៀងស្រះ)



រូបភាព ១២ : ការរៀបចំបៀវតាមទូរ (នៅដើមរដូវវស្សា)

### គ. របៀបជីកប្រព័ន្ធប្រឡាយក្នុងស្រែ

ការជីកប្រព័ន្ធប្រឡាយក្នុងស្រែដែលតភ្ជាប់ជាមួយស្រះមានសារៈសំខាន់ ដូចជា ស្តុកទឹកក្នុងស្រែអាកាសធាតុក្តៅត្រីចូលជ្រក។ ទទឹងមាត់ប្រឡាយលើពី ១,៥ - ២ ម៉ែត្រ និងទទឹងបាតប្រឡាយពី ១ - ១,៥ ម៉ែត្រ (រាងជាស្នូកដាក់បាយជ្រូក) ហើយជំរៅប្រឡាយពី ០,៥ - ១ ម៉ែត្រ។ ជញ្ជាំងប្រឡាយមានជើងទេរ (មិនចោតចុះពេក)។ ទំនប់មេកំពស់ ០,៦ ម៉ែត្រ និងកំពស់ទំនប់កូនពី ០,២ - ០,៣ ម៉ែត្រ (ងាយអោយត្រីចេញចូលពីស្រែមកក្នុងប្រឡាយរកចំណីស៊ី)។ បាតប្រឡាយរាប ប៉ុន្តែទេរមករកកន្លែងរង្វះបញ្ចេញបញ្ចូលទឹក។ ការជីកប្រឡាយក្នុងស្រែមានទំហំពី ១០ - ២០ ភាគរយ ធៀបនឹងផ្ទៃស្រែទាំងមូល។ នៅលើខ្នងទំនប់យើងគួរដាំបន្លែ ដូចជា ស្ពៃ ត្រកួន ប៉េងប៉ោះ ជំឡូងជ្វា កន្ធំថេត អង្កាដី ធ្វើជាចំណីត្រី។




**រូបភាព ១៣ : រូបកាត់ទទឹងប្រឡាយ (មើលពីទំហេងប្រឡាយ)**



**រូបភាព ១៧ : បាចជីលាមកសត្វទ្រាប់បាតប្រឡាយ**

ក្រោយពីដាក់ជីទ្រាប់បាតស្រះរួច គួរបញ្ចូលទឹកក្នុងស្រះមានកំពស់ទឹក 0,៥ ម៉ែត្រ ហើយត្រាំទុក ៥ ថ្ងៃ ឬ ១ អាទិត្យ ដើម្បីអោយចំណីធម្មជាតិកកើត។ ចុងក្រោយត្រូវបន្ថែមទឹកចូលស្រះ ឬ ប្រឡាយ តាមតំរូវការ។ បន្ទាប់ពីទុកបានពី ៥ - ៦ ថ្ងៃ យើងសង្កេតឃើញទឹកមានពណ៌បៃតង (ចំណីធម្មជាតិកើតឡើង) ទើបលែងកូនត្រី។

### ឆ. ការរៀបចំស្រះ ត្បៀរ និងប្រឡាយចាស់

ដំបូងពង្រីងទឹកអោយអស់ពីបាតស្រះប្រមូលត្រីចេញ។ សំអាតស្មៅ ឬ រុក្ខជាតិដែលដុះជុំវិញមាត់ស្រះ ឬ ប្រឡាយ។ ជួសជុលទំនប់ ជញ្ជាំង និងបាតស្រះ ឬ ប្រឡាយអោយកំនើនភាពរឹងមាំ។ ស្តារ និងសំអាតបាតស្រះ ឬ ប្រឡាយ។ រក្សាភក់ចាស់បាតស្រះកំរាស់ពី ២ - ៣ តឹក រួចបាចកំបោរសពី ៣ - ៥ គីឡូក្រាមក្នុងស្រះ ១០០ ម៉ែត្រការេ។ ហាលបាតស្រះ ឬ ប្រឡាយពី ១ - ៣ ថ្ងៃ ដើម្បីកាត់បន្ថយជាតិជូរ ឬ ប្រៃ សំលាប់មេរោគ ទឹកងាយថ្លា និងចំណីធម្មជាតិងាយកើត។

ដាក់ជីលាមកសត្វ និងរុក្ខជាតិទ្រាប់បាតស្រះ ឬ ប្រឡាយ ក្នុង ១០០ ម៉ែត្រការេនៃផ្ទៃស្រះ រួមមាន:

- លាមកគោ ឬក្របី : ៣០ - ៤០ គីឡូក្រាម
- លាមកមាន់ (បើមាន) : ២ - ៣ គីឡូក្រាម
- ជីកំប៉ុស្ត : ៧ - ១០ គីឡូក្រាម
- ទន្រ្ទានខែត្រ (ចងជាបាច់) : ២០ - ៣០ គីឡូក្រាម



**រូបភាព ១៨ : បាចកំបោរស្ងួតលាលផ្ទៃបាតស្រះ**

ក្រោយពីដាក់ជីទ្រាប់បាតស្រះរួចបញ្ចូលទឹកក្នុងស្រះកំរិតទឹក ៥ តឹក ហើយរក្សាទឹក ៣ - ៥ ថ្ងៃ ឬ ១ អាទិត្យ។ ចុងក្រោយបន្ថែមទឹកចូលស្រះ ឬ ប្រឡាយ តាមតំរូវការ។ ក្រោយពីបានពី ៤ - ៥ ថ្ងៃ យើងសង្កេតឃើញទឹកពណ៌បៃតង (ចំណីធម្មជាតិកើត)។

## ផ. របៀបរៀបចំជំរកត្រី

ការធ្វើជំរកត្រីមានសារៈសំខាន់ ដូចជា កន្លែងត្រីលាក់ខ្លួន និងពងកូន។ វាជាតំរូវការចរិតរស់នៅត្រីស្រែ ពីព្រោះត្រីស្រែចូលចិត្តពួនលាក់ខ្លួន។ ត្រីស្រែភាគច្រើនចេញរកចំណីស៊ីនៅពេលព្រលប់រហូតដល់ភ្លឺ (ថ្ងៃរះ) ជាពិសេសពេលមានភ្លៀង។ នៅពេលថ្ងៃ ត្រីស្រែមិនសូវមានសកម្មភាពចេញមករកចំណីទេ (សង្ងំលាក់ខ្លួន)។ ដូចនេះយើងត្រូវបង្កើតជំរកអោយត្រី រួមមាន *ជំរកបាត* និង*ជំរកលើ* (លើផ្ទៃទឹក)។

☞ **ជំរកបាត** (ដាក់គល់ឈើ ឬ មែកឈើងាប់នៅបាតស្រះ)

យើងត្រូវរៀបចំជំរកត្រីនៅបាតស្រះ បៀវ ប្រឡាយ ក្រោយពីរៀបចំស្រះ (សំអាតស្រះ ដាក់ជី) រួចហើយទើបបញ្ចូលទឹក។

សារៈប្រយោជន៍នៃការរៀបចំជំរកបាតអោយត្រីៈ

- ជាកន្លែងត្រីលាក់ខ្លួនពេលមានគ្រោះភ័យខ្លាច
- ជាកន្លែងធ្វើសំបុកពង ដូចជា ត្រីអណ្តែង ត្រីឆ្លាត ត្រីដំរី (ជាប្រភេទត្រីពងតោង)
- ជាកន្លែងពួនគេចពីសត្រូវ (ត្រីធំដេញត្របាក់ស៊ីត្រីតូច)
- ស្លែដុះតោងជាប់នឹងគល់ឈើធ្វើជាចំណីត្រី
- ត្រីអាចគេចពីមនុស្សលួចចាប់
- ត្រីចូលជំរកពេលអាកាសធាតុក្តៅ

ជំរកបាតស្រះ (សំរាស់បាតស្រះ) ដាក់គល់ស្វាយ គល់-មែកអំពិលទឹក គល់ឫស្សី គល់រំចេក មែកសង្កែ និងគល់ដើមត្នោតងាប់ ។ល។ ការធ្វើជំរកបាតទំហំពី ៥ - ១០ ម៉ែត្រការេ ក្នុង ១០០ ម៉ែត្រការេនៃ ផ្ទៃស្រះ។ ការដាក់ជំរកនេះធ្វើយ៉ាងណាអោយមានផ្លូវ (រូង) ត្រីហែលចេញចូល ។



**រូបភាព ១៩ : ជំរកបាតស្រះ (គល់ឈើ)**

☞ **ជំរកលើផ្ទៃទឹក** (ដោតចុងឫស្សី ឬ មែកអំពិលទឹក និងដាំកំប្លោក កំពឹងពួយ កញ្ឆែត ត្រកួន ស្មៅទឹក)

សារៈប្រយោជន៍នៃការរៀបចំជំរកលើអោយត្រីៈ

- លាក់ខ្លួនពេលមានគ្រោះភ័យខ្លាច សង្វំលាក់ខ្លួនចាំចាប់ចំណី
- ធ្វើសំបុកពងដូចជា ត្រីកន្ធរ ត្រីផ្ទក់ ត្រីក្រាញ់
- ទាក់ទាញកូនសត្វល្អិត១ ជាចំណីត្រី ត្រីចូលជ្រកពេលអាកាសធាតុក្តៅ
- អាចគេចពីការចាប់របស់មនុស្ស
- ឫសរុក្ខជាតិខ្លះជាចំណីត្រី

ការរៀបចំជំរកត្រីនៅលើផ្ទៃទឹកស្រះ បៀវ និងប្រឡាយ ក្រោយពីបានរៀបចំសំអាតស្រះ ដាក់ជី និង បញ្ចូលទឹកដោយដោតចុងឫស្សី មែកអំពិលទឹក ដើម្បីអោយកំប្លោក ត្រកួន កំពឹងពួយ កញ្ឆែតដុះរុំ ។

<u>**របៀបរៀបចំជំរកលើៈ**</u> ដំបូងបោះចុងឫស្សី ឬ មែកអំពិលទឹកទៅនឹងបាតស្រះទំហំពី ៥ - ១០ ម៉ែត្រការេ ក្នុង ១០០ ម៉ែត្រការេនៃផ្ទៃស្រះ រួចហើយដាំកំប្លោក កំពឹងពួយ ស្មៅត្រីប កញ្ឆែត ស្មៅទឹកដាក់ចំកណ្តាលស្រះ ។



**រូបភាព ២០ ៖ រុក្ខជាតិឈើផ្លែទឹក (កំប្លោក កញ្ឆែត និងត្រកួន) នៅទំនប់ឆ្លាស្រះ**

### ឃ. ប្រភពទឹក

ប្រភពទឹកជាកត្តាសំខាន់បំផុតសំរាប់ជីវិតមច្ឆាជាតិ ដូចជា ទឹកភ្លៀង ព្រែក បឹងបួរ ស្ទឹង ទន្លេ ប្រព័ន្ធប្រឡាយទឹក និង ទឹកក្រោមដី ឬ ទឹកអណ្តូង ។

## ៤.៣. ការគ្រប់គ្រងត្រីមេពូជ

### ៤.៣.១. ជ្រើសរើសត្រីមេពូជ និងការលែងត្រីមេពូជ

ការជ្រើសរើសត្រីមេពូជជាកត្តាមួយយ៉ាងសំខាន់ គឺការចូលរួមបន្តពូជ បង្កបង្កើតពងកូន (ឆាប់បង្កើតបានកូនចៅជំនាន់ក្រោយ) និងឆាប់បានទទួលផលវិញ។ ដើម្បីជ្រើសរើសត្រីមេពូជយើងសំគាល់លើ ដងខ្លួនត្រីដែលត្រូវមានទ្រង់ទ្រាយល្អ (កាយសម្បទាល្អ) មានសុខភាពមាំមួន ពណ៌សម្បុរភ្លឺស្រស់ មិនមានស្លាកស្នាមដាច់ ឬ របាកលើស្បែកស្រកាឡើយ។ ជៀសវាងការជ្រើសរើសត្រីមេពូជពីការចាប់ដោយប្រើឧបករណ៍ឆក់ ឬ ចាក់ (ស្ន ឬ ឧបករណ៍ ធ្វើអោយត្រីដាច់របាកស្រកា ឬ ស្បែក) មកធ្វើជាត្រីមេពូជ ពីព្រោះវាអាចបាត់បង់ ឬ ប៉ះពាល់ប្រព័ន្ធសរីរាង្គបន្តពូជធ្វើអោយត្រីមិនអាចចូលរួមបន្តពូជ និងគ្មានពង ឬ អភេទ។

ការជ្រើសរើសត្រីមេពូជមកដាក់ធ្វើពូជបន្តអាចសំគាល់បានតាមលក្ខណៈសាមញ្ញៗ ដូចជា ពណ៌សម្បុរ និងភិនភាគខាងក្រៅនៃប្រភេទត្រីនីមួយៗ។

៤.៣.២ លក្ខណៈសំគាល់ត្រីមេពូជញី និងឈ្មោល:

ក. ត្រីកន្ធរ

<u>ត្រីញី:</u> មានដងខ្លួនមូលខ្លី ពោះធំទន់ស្មើ នៅលើខ្លួនមានស្នាមឆ្នូតទទឹងខ្លួនពណ៌ខ្មៅលេចចេញមិនច្បាស់ ។ ព្រុយឆ្អឹងខ្នងខ្លីមិនដុះដល់គល់ព្រុយកន្ទុយ ។

<u>ត្រីឈ្មោល:</u> នៅលើខ្លួនមានឆ្នូតទទឹងខ្លួនពណ៌ខ្មៅ លេចចេញច្បាស់ពីខ្នងមកពោះ។ ព្រុយឆ្អឹងខ្នងដុះវែងដល់គល់ព្រុយកន្ទុយ ។

- អាយុពី ៧ - ១០ ខែ ពេញវ័យបន្តពូជ ( មានពង)
- ទំងន់ពី ៨០ - ១០០ ក្រាម ឬ ២០០ ក្រាម ក្នុង ១ ក្បាល
- លែងត្រីមេពូជ ពី ៤ - ៦ ក្បាល ក្នុង ១ ម$^{២}$ នៃផ្ទៃស្រះ ឬ បៀវ
- ពេលលែងត្រូវមានសមាមាត្រញីឈ្មោលគឺ ញី ១ ក្បាល និងឈ្មោល ១ ក្បាល ( ១ គូ) ។



**រូបភាព ២១ : មេពូជត្រីកន្ធរ (រូបលើត្រីឈ្មោល និងក្រោមត្រីញី)**

៦. ត្រីផ្ទក់

ត្រីញី : ក្បាលធំ ដងខ្លួនធាត់ខ្លី ពោះធំទន់ រន្ធបន្តពូជក្បែររន្ធលាមក។ លើដងខ្លួនមានឆ្នូតទទឹងខ្លួនពណ៌ប្រផេះស្រាល (មិនច្បាស់ដូចត្រីឈ្មោល) ចាប់ពីព្រុយទ្រូងរហូតដល់ព្រុយបន្តពូជ។

ត្រីឈ្មោល : ក្បាលតូច ដងខ្លួនវែង ពោះតូចរឹង រន្ធបន្តពូជឃ្លាតឆ្ងាយពីរន្ធលាមក។ ឆ្នូតទទឹងខ្លួនពណ៌ប្រផេះលើដងខ្លួនពីព្រុយទ្រូងដល់ព្រុយបន្តពូជ ។

- អាយុពី ៧ - ១០ ខែ ពេញវ័យបន្តពូជ (មានពង)
- ទំងន់ពី ០,៣ - ១ គីឡូក្រាមក្នុង ១ ក្បាល
- លែងត្រីមេពូជពី ២ - ៣ គីឡូក្រាមក្នុង ១០ ម$^2$ នៃផ្ទៃស្រះ ឬ បៀរ
- ពេលលែងត្រូវមានសមាមាត្រញីឈ្មោលគឺ ត្រីញី ១ ក្បាល និងត្រីឈ្មោល ២ ក្បាល។



**រូបភាព ២២ : មេពូជត្រីផ្ទក់ (រូបលើត្រីឈ្មោល និងក្រោមត្រីញី)**

គ. ត្រីក្រាញ់

<u>ត្រីញី</u> : ខ្លួនធាត់ខ្លី ពោះធំទន់ស្មើ រន្ធបន្តពូជពណ៌ផ្កាឈូក ។

<u>ត្រីឈ្មោល</u> : ដងខ្លួនស្ទើរសំប៉ែតទ្រវែង ពោះតូចរឹង ពេលយកដៃច្បូតពោះមានទឹកស្លែមហូរចេញ (ពេលពេញវ័យ) ។

- អាយុពី ៨ - ១០ ខែ ពេញវ័យបន្តពូជ (មានពង)
- ទំងន់ពី ៣០ - ៧០ ក្រាម ក្នុង ១ ក្បាល
- មេពូជលែងពី ០,៥ គ.ក្រ (៤ - ៦ ក្បាល) ក្នុង ១ ម$^{២}$ នៃផ្ទៃស្រះ ឬ ប្រៀវ
- ពេលលែងត្រូវមានសមាមាត្រញីឈ្មោលគឺ ត្រីញី ១ ក្បាល និងត្រីឈ្មោល ២ ក្បាល ។



**រូបភាព ២៣ : មេពូជត្រីក្រាញ់ (រូបខាងលើត្រីឈ្មោល និងក្រោមត្រីញី)**

ឃ. ត្រីអណ្ដែង

ត្រីញី : ដងខ្លួនធាត់ខ្លី ពោះធំទន់ រន្ធបន្តពូជធំមូលពណ៌ផ្កាឈូកលយចេញ ។

ត្រីឈ្មោល : ដងខ្លួនមូលទ្រវែង ពោះរឹងតូច រន្ធបន្តពូជតូចមូល ។

- អាយុពី ៨ - ១២ ខែ ពេញវ័យបន្តពូជ ( មានពង)
- ទំងន់ពី ១,៥ - ២ ខាំ ក្នុង ១ ក្បាល
- លែងត្រីមេពូជពី ១ - ១,៥ គ.ក្រ ក្នុង ១ ម$^{២}$ នៃផ្ទៃស្រះ ឬ ហ្បៀវ
- ពេលលែងត្រូវមានសមាមាត្រញីឈ្មោលគឺ ញី ១ ក្បាល ឈ្មោល ២ ក្បាល ។



រូបភាព ២៤ : ត្រីអណ្ដែង (រូបលើត្រីអណ្ដែងទន់ និងក្រោមត្រីអណ្ដែងរឹង)

ង. ត្រីដីរ

ត្រីញី : ក្បាលធំ ដងខ្លួនធាត់ខ្លី ពោះធំទន់ រន្ធបន្តពូជមានបំពង់ធំមូលលយចេញវែង ខាងចុងមានពណ៌ក្រហម ឬ ផ្កាឈូក។ ដងខ្លួនមានពណ៌ប្រផេះដុំៗ ច្បាស់ និងស្រអាប់ ( ប្រផេះ) ជាងត្រីឈ្មោល។

ត្រីឈ្មោល : ក្បាលតូច ដងខ្លួនធាត់ខ្លី ពោះធំទន់ រន្ធបន្តពូជមានបំពង់តូចមូលលយចេញខ្លី ខាងចុងមានពណ៌ផ្កាឈូក ឬ ពណ៌ស។ ដងខ្លួនមានពណ៌លឿង និងប្រផេះដុំៗ មិនច្បាស់ ដូចត្រីញី។ ដងខ្លួនមានពណ៌ស្រស់ ថ្លា (លឿង) ជាងត្រីញី។ ពេលត្រីដល់អាយុពេញវ័យ (ចូលដល់វ័យបន្តពូជ) ច្បូតពោះមានទឹកស្ពែមហូរចេញមកក្រៅមានពណ៌ទឹកដោះគោ។

- អាយុពី ៩ - ១២ ខែ ពេញវ័យបន្តពូជ ( មានពង)
- ទំងន់ពី ៣ ខាំ - ៦ ខាំ ក្នុង ១ ក្បាល
- លែងត្រីមេពូជពី ១ - ១,៥ គ.ក្រ ក្នុង ១ ម$^{២}$ នៃផ្ទៃស្រះ ឬ បៀរ
- ពេលលែងត្រូវមានសមាមាត្រញីឈ្មោលគឺ ញី ១ ក្បាល ឈ្មោល ២ ក្បាល ។



**រូបភាព ២៥ : មេពូជត្រីដីរ (រូបខាងលើត្រីឈ្មោល និងក្រោមត្រីញី)**

### ៤.៣.៣. លក្ខខណ្ឌអោយត្រីស្គាល់ជំរក

- ត្រូវថែទាំកូនត្រីរហូតដល់ត្រីធំពេញវ័យ
- ការរៀបចំស្រះ ឬ បៀវ ធ្វើជំរក (លើ និងបាត) ផ្តល់ចំណី និងគ្រប់គ្រងបានល្អ
- ត្រូវការពារ ដូចជា ការឆក់ ថ្នាំពុល ការរំខានដល់ការរស់នៅ
- ផ្តល់ចំណីបន្ថែម ដូចជា កន្ទក់ ចុងអង្ករ កាកសំណល់ផ្ទះបាយ ជីកំប៉ុស្ត ការផ្គត់ផ្គង់គុណភាពទឹក
- រក្សាពពួកត្រីតូចៗ ពីព្រោះវាជាចំណីត្រីធំ ។

## ៤.៤. ការផ្តល់ចំណីបន្ថែម

ប្រភេទចំណីត្រី ដូចជា សារាយ ត្រកួន ចកពងទឹក ចកបាយទា បន្លែ ពោត ដំឡូងជ្វា កន្ទក់ ចុងអង្ករ សំណល់សត្តឃាដ កាកសំណល់ផ្ទះបាយ បាយស្រោ ជីកំប៉ុស្ត និងកូនសត្វ ដូចជា កណ្តៀរ អង្រ្កង ជន្លេន មេភ្លៀង ខ្យង ចង្រិត ដង្កូវ ។ល។ ជាពិសេសការបាចកន្ទក់ អាចជួយទាក់ទាញពពួកត្រីតូចៗ មកពងកូនអោយច្រើន នៅក្នុងជំរកពីព្រោះវាជាចំណីត្រីធំ (ត្រីផ្ទក់ ក្រាញ់ អណ្តែង ...) ។




**រូបភាព ២៦ : កូនសត្វជាចំណីត្រី**




**រូបភាព ២៧ : ធាតុផ្សំជាចំណីត្រី (រុក្ខជាតិបៃតង និង កន្ទក់ ចុងអង្ករ ពោត...)**

### ក. ពេលវេលាផ្តល់ចំណី

ផ្តល់ចំណីអោយត្រីស៊ី ១ - ២ ដង ក្នុង ១ ថ្ងៃ, ព្រឹក ( ម៉ោង ៧ - ៨ ) និងល្ងាច ( ម៉ោង ៤ - ៥) ពីព្រោះទឹកត្រជាក់មិនធ្វើអោយប៉ះពាល់ដល់ប្រព័ន្ធរំលាយអាហារ និងការដកដង្ហើមរបស់ត្រី ហើយត្រីចាប់ចំណីស៊ីពេលមេឃត្រជាក់។ បរិមាណចំណីត្រូវត្រួតពិនិត្យចំណីដែលនៅក្នុងកញ្ច្រែងដាក់ចំណី។ បើសិនត្រីតូចកើតច្រើន ត្រីធំក៏នៅច្រើនដែរ ពីព្រោះត្រីតូចៗ ជាចំណីត្រីធំ។



**រូបភាព ២៨ : ការផ្សំចំណីអោយត្រីស៊ី (កន្ទក់ ចុងអង្ករ ត្រកួន ដើមចេក...)**

## ខ. ទីកន្លែងអោយចំណី

- កន្លែងដាក់ចំណីៈ ធ្វើស៊ុមដាក់ចំណីនៅកន្លែងរាក់ ( ជំរៅ ០.៥ ម៉ែត្រ) ងាយស្រួលអង្កេតមើលត្រី (ចំនួនត្រី និងសុខភាពត្រី)
- ពេលវេលាផ្តល់ចំណីៈ អោយចំណីត្រីស៊ីទៀងទាត់ ( ព្រឹក - ល្ងាច) ។



**រូបភាព ២៩ : ស៊ុមដាក់ចំណីត្រីបន្លែស្រស់ (ចកបាយទា ស្លែ ត្រកួន ស្លឹកដំឡូងជ្វា)**

ចំពោះប្រភេទចំណីបន្ថែមដូចជា សារាយ ត្រកួន ចកពងទឹក ចកបាយទា បន្លែ ស្លឹកអង្កាដី ស្លឹក និងផ្លែកន្ទុំថេត ពោត ស្លឹកដំឡូងជ្វា កណ្ដៀរ អង្រ្កង ដង្កូវ ជន្លេន កាកសំណល់ផ្ទះបាយ ។ល។



**រូបភាព ៣០ : ពិនិត្យចំណីដែលត្រូវផ្តល់បន្ថែម និងចំនួនត្រី**

ការបន្ថែមជីរុក្ខជាតិ និងជីលាមកសត្វ ១ - ២ ដង ក្នុង ១ ខែ ស្មើនឹង ៣០ - ៤០ ភាគរយ ពេលរៀបចំស្រះដំបូង ។ ត្រីស្រែចូលចិត្តចេញរកចំណីនៅពេលព្រលប់ ។

ការផ្តល់ចំណីនេះដំបូងគឺ ចំណីផ្តល់អោយពពួកត្រីល្អិតៗមកស៊ីជាសំខាន់ ដូចជា ត្រីចង្វារ កំពឹស ត្រីកំភ្លាញ ។ល។ បន្ទាប់ពីពពួកត្រីតូចកកើតច្រើនជាចំណីត្រីធំ ដូចជា ត្រីផ្ទក់ ត្រីអណ្តែង ត្រីក្រាញ់ ត្រីឆ្ពិន ។ល។ នេះជាវិធីទាក់ទាញត្រីស្រែអោយមកចូលក្នុងជំរក (ស្រះ បឿរ ប្រឡាយ) ។ ក្រៅពីនេះ នៅពេលយប់ ដាក់ចង្កៀងលើផ្ទៃទឹកស្រះ ដើម្បីទាក់ទាញកូនសត្វល្អិតមានរោមវានឹងអាចធ្លាក់ចុះជាចំណីត្រី ។



**រូបភាព ៣១ : ដាក់ចន្លឹះចង្កៀងទាក់ទាញកូនសត្វល្អិតៗជាចំណីត្រី**

## ៤.៥. ការថែទាំ និងការពារត្រី

ការទាក់ទាញត្រីធម្មជាតិ គឺការធ្វើជំរក ទុកមេពូជ ផ្គត់ផ្គង់ទឹក និងផ្តល់ចំណីបន្ថែម ដើម្បីទទួលបានផលខ្ពស់ជាងមុន ត្រូវយកចិត្តទុកដាក់ និងថែបំប៉ន ដូចខាងក្រោម :

### ក. ដាក់ជីបន្ថែម

ត្រូតពិនិត្យពណ៌ទឹកបែតងចាស់ត្រូវបន្ថយ ឬ ផ្អាកការដាក់ជី ។ បើទឹកថ្លាត្រូវដាក់ជី (លាមកសត្វ និងរុក្ខជាតិ) ទៅតាមការជាក់ស្តែងនៃទឹកស្រះ ។

### ខ. ផ្តល់ចំណីបន្ថែម

ចំណីផ្តល់បន្ថែមដូចជា បន្លែស្រស់ ត្រូវហាន់ ឬ បុកអោយល្អិត ដូចជា ត្រកួន ដើមចេក ស្លឹកដំឡូងជ្វា។ ចំពោះ សារាយ ចកបាយទា ចកពងទឹក ដាក់ក្នុងស៊ុម។ ចំពោះកណ្តៀវរវែងយកដីចេញ។ ចំណីកន្ទក់ទាក់ទាញកូនត្រីតូចៗ អោយឆាប់កើតកូនសំរាប់ចំណីត្រីធំ។



**រូបភាព ៣២ : ចិញ្ច្រាំបន្លែស្រស់អោយត្រីស៊ី**

### គ. ទំហំជំរកលើផ្ទៃស្រះ និងបៀវ

រក្សាទំហំជំរកលើពី ២ - ៣ ម$^{២}$ ក្នុងស្រះ ១០០ ម៉ែត្រការេ។ កុំប៉ះពាល់ជំរកនេះព្រោះវាអាចរំខានដល់ការពងកូន និងបែកសំបុករបស់ត្រី។

### ឃ. រុក្ខជាតិ

ដាំរុក្ខជាតិតាមមាត់ស្រះ បៀវ ប្រឡាយ ដូចជា ត្រាវ ដើមស្នោ ត្រកួន កញ្ឆែត ត្រកៀត។ ជៀសវាងការដាំឈូកក្នុងស្រះ បៀវ ប្រឡាយ ពីព្រោះត្រីហែលអាចប៉ះរលាក ឬ ដាច់ស្រកា ស្បែក បង្កជាដំបៅ។

### ង. ផែនទាំ

ជៀសវាងការឆក់ ការប្រើថ្នាំពុល ការចាប់កូនត្រី និងត្រីមេពូជ បូមផ្តាច់ពូជត្រី និងត្រីពងកូន។

### ច. ជំរៅទឹក

ទឹកក្នុងស្រះ និងប្រឡាយ កុំអោយរាក់ពេកពីព្រោះធ្វើអោយទឹកក្តៅ ដែលនាំអោយត្រីងាប់។

### ឆ. វង្វះទឹក

បើកច្រកផ្លូវទូលាយអោយត្រីចេញចូលទៅមកស្រះ ប្រឡាយ។

## ៤.៦. ការប្រមូលផលត្រី

ការប្រមូលផលត្រីជាកត្តាមួយសំខាន់ដែលទាក់ទងនឹងទីផ្សារ និងការរក្សាទុកពូជត្រី។ គប្បីស្វែងយល់ចំនុចមួយចំនួនដូចខាងក្រោម :

- ប្រមូលផលត្រីនៅព្រឹក ឬ ពេលមេឃត្រជាក់
- ប្រើឧបករណ៍សាមញ្ញ ដូចជា អួន អង្រុត ស្នូច បាច
- មិនបូមផ្តាច់ពូជត្រី មិនប្រើឧបករណ៍ឆក់ ឬ ថ្នាំពុលក្នុងការប្រមូលផលត្រី
- កុំប្រមូលផលត្រីពេលស្រែរីងស្ងួត (ខែផល្គុន - ចែត្រ) ធ្វើអោយពងត្រី កូនត្រីតូចៗ និងចំណីធម្មជាតិងាប់ ពីព្រោះទទួលរងចំហាយកំដៅដី។
- ពេលប្រមូលត្រីត្រូវមានកន្លែងស្តុកទឹក ដើម្បីងាយស្រួលក្នុងការបញ្ចូលទឹកមកស្រះវិញកុំអោយត្រីល្អិតៗ និងចំណីធម្មជាតិងាប់។
- ជ្រើសរើសត្រីធំល្អៗទុកធ្វើមេពូជ ពី ៣ - ៥ គ.ក្រ ក្នុង ១ គ្រួសារ (គ្រប់ប្រភេទត្រី) ។



រូបភាព ៣៣ : ស៊ុមឈើក្រាលកៅស៊ូសំរាប់ស្តុកត្រីមេពូជពេលប្រមូលផល (ទុកដែលចំទូលស្រះវិញ)

## ៤.៧. ការរក្សាទុកមេពូជត្រីចំរុះ



**រូបភាព ៣៤ : ថ្លុករក្សាទុកត្រីមេពូជនៅក្បែរអណ្តូងទឹក (ទុកពូជឆ្នាំបន្ត)**

- រៀបចំបៀវតូច ( ៥០ម$^{២}$ ) នៅកន្លែងណាមួយក្នុងការផ្គត់ផ្គង់ទឹក និងទុកត្រីមេពូជ
- រក្សាពូជប្រភេទត្រីល្អិតៗកុំអោយដាច់ពូជ ដូចជា កំពឹស ត្រីចង្វារ កំភ្លាញ ក្រឹម ក្រាញ់...
- ជីកបៀវ ឬ ថ្លុក (នៅក្បែរផ្ទះ) ទំហំពី ៣០ - ៥០ ម៉ែត្រការេក្នុងមួយគ្រួសារ និងមានអណ្តូងទឹកសំរាប់ជួយផ្គត់ផ្គង់ដល់មេត្រីពូជ
- នៅរដូវប្រាំង (អត់ទឹក) ប្រមូលត្រីដែលទុកពូជយកទៅលែងស្រះវត្ត ស្រះរួម ឬ ផ្ញើទុកគ្រួសារដែលមានប្រភពទឹក ឬ មានអណ្តូងទឹក ។



**រូបភាព ៣៥ : ការលែងត្រីមេពូជ (នៅដើមរដូវវស្សា)**

## ៤.៨. វិធីការពារ និងព្យាបាលជំងឺ

ត្រីរស់នៅក្នុងទឹកតែងតែមានជំងឺដោយសារកត្តាមួយចំនួនដូចជា :

- មជ្ឈដ្ឋានរស់នៅ(ទឹក): ពន្លឺចូលស្រះមិនគ្រប់គ្រាន់ ទឹកគ្មានគុណភាព បាតស្រះមានសារធាតុជាតិពុលច្រើន និងសារធាតុពីក្រៅហូរចូល ។
- ការបង្កជំងឺ: វីរុស បាក់តេរី ពពួកផ្សិត និងបរាសិត ( ពពួកសត្វល្អិតខាំតោងជាប់ខ្លួនត្រី)
- ភ្នាក់ងារចំលង: ក្តាម កង្កែប ត្រី អន្ទង់ ពស់ ក្តាម មនុស្ស ទឹក ។ល ។

### ក ការពារជំងឺ

- រក្សាមជ្ឈដ្ឋានរស់នៅរបស់ត្រី ( ទឹកល្អជានិច្ច) គ្មានសារធាតុគីមីហូរចូល ( ថ្នាំពុល ឬ ជីគីមី)
- ក្រោយពេលប្រមូលផលត្រីត្រូវកាយប្រមូលកាកសំណល់នៅស្រះ រៀបចំស្រះ ( បាចកំបោរស)
- ប្រើអញ្ចង ឬ អួន ដើម្បីកៀរបំបែកសារធាតុផ្សេងៗ នៅបាតស្រះអោយភាយឡើង មកបរិយាកាស និងកុំអោយមេរោគផ្គុំគ្នាបង្កើតឡើង ( កៀរ ១ - ២ ដង ក្នុង ១ ខែ) ។

### ខ ព្យាបាលជំងឺ

ត្រីមានជំងឺហែលយឺត បណ្តែតខ្លួនលើផ្ទៃស្រះ ហែលសសៀរតាមមាត់ស្រះ ហាមាត់ស្រូបយកខ្យល់ពីបរិយាកាស និងមិនស៊ីចំណី ។

- ប្រើស្ពឺកស្ពោៈ ៣ - ៥ គ.ក្រ ក្នុងស្រះ ១០០ម$^{២}$ ។ ចងជាបាច់ដាក់នៅបាតស្រះ ឬ ចិញ្ច្រាំដាក់ចូលក្នុងថង់ក្រណាត់ដាក់នៅបាតស្រះដែលមានត្រីកើតជំងឺ ថង់មានចោះរន្ធតូចៗ ។
- ប្រើកំបោរស ១ - ២ គីឡូក្រាម លាយជាមួយទឹក ៣០ លីត្រ ក្នុងស្រះ ១០០ម$^{២}$ ។ បាចជុំវិញមាត់ស្រះ, រយៈពេល ៤ - ៥ ថ្ងៃ ( ១ ថ្ងៃ បាច ១ ដង) ។
- ប្រើអំបិល ១ - ២ គីឡូក្រាម លាយជាមួយទឹក ៣០ លីត្រ ក្នុងស្រះ ១០០ម$^{២}$ ។ បាចជុំវិញមាត់ស្រះ, រយៈពេល ៤ - ៥ ថ្ងៃ ( ១ ថ្ងៃ បាច ១ ដង) ។

## ៥. បទពិសោធន៍សំខាន់ៗរបស់កសិករក្នុងការទាក់ទាញត្រីធម្មជាតិ

### ៥.១ បទពិសោធន៍កសិករ កែវ ថូ

បងប្រុស កែវ ថូ ជាកសិករនៅភូមិអកពង ឃុំគួស ស្រុកត្រាំកក់ ខេត្តតាកែវ ។ គាត់មានបទពិសោធន៍ក្នុងការទាក់ទាញត្រីធម្មជាតិតាមបច្ចេកទេសថ្មី។ ស្រះរបស់គាត់មានទំហំ ១៤៣ ម៉ែត្រការេ និងជំរៅ ១,៧ ម៉ែត្រ។ កន្លងមកការទាក់ទាញត្រីធម្មជាតិតាមទំលាប់គាត់បានទទួលផលត្រី ២០ គីឡូក្រាមប៉ុណ្ណោះ តែក្រោយពីបានអនុវត្តនូវគំនិតថ្មី គាត់ទទួលផលត្រីបានជាង ៨១ គីឡូក្រាម ។ បទពិសោធន៍ដែលទទួលផលបានខ្ពស់របស់គាត់បង្ហាញជូនដូចខាងក្រោម :

**ក. ការរៀបចំស្រះ**

- ស្តារភក់បាតស្រះ និង កាត់មែកឈើជុំវិញមាត់ស្រះ
- បើករង្វះទឹក ២ ច្រក
- ដាក់គល់ឈើបាតស្រះ (ទំហំសំរាស់ដាក់បាតស្រះ ៧ ម៉ែត្រការេ)
- ដាំកំប្លោក និងកំពឹងពួយ អោយដុះរុំចុងឫស្សីដែលដោតកណ្តាលស្រះ (ទំហំជំរកលើផ្ទៃស្រះ ៧ ម៉ែត្រការេ) ។

**ខ. បង្កើតចំណីធម្មជាតិ**

- ដាក់លាមកគោ ២៥ គីឡូក្រាម
- ទន្រ្ទានខែត្រ ២៥ គីឡូក្រាម ។

**គ. ការផ្តល់ចំណី**

- ចំណីដែលផ្តល់អោយត្រីស៊ីមានដូចជា កន្ទក់ និងកណ្ដៀរ
- កន្ទក់ ០,៣ គីឡូក្រាម ក្នុង ១ ថ្ងៃ ចែកជា ៣ ពេល (ព្រឹក ថ្ងៃត្រង់ និងល្ងាច)
- ចំពោះកណ្ដៀរ ២ ដងក្នុង ១ អាទិត្យ (មិនទៀងទាត់) ។

**ឃ. ការគ្រប់គ្រង និងថែទាំ**

- រក្សាកំប្លោក និងកំពឹងពួយដែលដុះធ្វើជាជំរកលើមិនអោយដុះលើស ៧ ម៉ែត្រការេ
- ការពារមនុស្សឆក់
- ផ្តល់ចំណីពី ៣ - ៤ ថ្ងៃក្នុង ១ អាទិត្យ ចាប់ពីដើមឆ្នាំរហូតដល់ប្រមូលផលត្រី ។

**ង. យោបល់បន្ថែម**

- គួរបាចកំបោរសពី ៣ - ៥ គីឡូក្រាម ក្នុងស្រះ ១០០ ម៉ែត្រការេ
- គួររក្សាមេត្រីពូជ ទុកក្នុងជំរកខ្លះ
- គួរមានប្រឡាយពីស្រែចូលស្រះ ។

## ៥.២ បទពិសោធន៍កសិករ មុំ សារុន

បងប្រុស មុំ សារុន ជាកសិករនៅភូមិអកពង ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ។ គាត់មានបទពិសោធន៍ក្នុងការទាក់ទាញត្រីធម្មជាតិតាមបច្ចេកទេសថ្មី។ ស្រះរបស់គាត់មានទំហំ ១៣២ ម៉ែត្រការេ និងជំរៅ ៣ ម៉ែត្រ។ កន្លងមកការទាក់ទាញត្រីធម្មជាតិតាមទំលាប់គាត់បានទទួលផលត្រី ៥ គីឡូក្រាមប៉ុណ្ណោះ តែក្រោយពីបានអនុវត្តនូវគំនិតថ្មី គាត់ទទួលផលត្រីបានជាង ២១ គីឡូក្រាម។ បទពិសោធន៍ដែលទទួលផលបានខ្ពស់របស់គាត់បង្ហាញជូនដូចខាងក្រោម :

### ក. ការរៀបចំស្រះ

- ស្តារភក់បាតស្រះ និង កាត់មែកឈើជុំវិញមាត់ស្រះ
- បើករង្វះទឹក ១ ច្រក
- ដាក់គល់ឈើបាតស្រះ ដូចជា មែកអំពិលទឹក ស្វាយ (ទំហំសំរាស់ដាក់បាតស្រះ ៥ ម៉ែត្រការេ)
- ដាំកំប្លោក កំពីងពួយ កញ្ឆែត ត្រកួន អោយដុះរុំចុងឬស្សីដែលដោតកណ្តាលស្រះ (ទំហំជំរកលើផ្ទៃស្រះ ៥ ម៉ែត្រការេ) ។

### ខ. បង្កើនចំណីធម្មជាតិ

- ដាក់លាមកគោ ១៥ គីឡូក្រាម
- ទន្រ្ទានខែត្រ ១០ គីឡូក្រាម ។

### គ. ការផ្តល់ចំណី

- ចំណីដែលផ្តល់អោយត្រីស៊ីមានដូចជា កន្ទក់ និងកណ្តៀរ
- ចំពោះកន្ទក់ ០,៣ គីឡូក្រាម ក្នុង ១ ថ្ងៃ ចែកជា ២ ពេល (ព្រឹក និងល្ងាច) ។

### ឃ. ការគ្រប់គ្រង និងថែទាំ

- រក្សាកំប្លោក និងកំពីងពួយដែលដុះធ្វើជាជំរកលើមិនអោយដុះលើ ៥ ភាគរយផ្ទៃស្រះ
- ស្រះរបស់គាត់មានម្លប់ស្វាយគ្របពីលើផ្ទៃស្រះប្រហែលជា ២០ ភាគរយ
- ការពារមនុស្សឆក់ និងទាចូលស៊ី
- ផ្តល់ចំណីពី ២ - ៣ ថ្ងៃក្នុង ១ អាទិត្យ ចាប់ពីដើមឆ្នាំរហូតដល់ប្រមូលផល ។

### ង. យោបល់បន្ថែម

- គួរបាចកំបោរស ៣ - ៥ គ.ក្រ ក្នុងស្រះទំហំ ១០០ ម៉ែត្រការេ
- គួរបើករង្វះទឹកពី ២ - ៣ ច្រកចូលមកស្រះ
- គួរជីកប្រព័ន្ធប្រឡាយចូលមកក្នុងស្រះ ។

## ៥.៣ បទពិសោធន៍កសិករ ជា ថន

បងប្រុស ជា ថន ជាកសិករនៅភូមិតាសួ ឃុំឧត្តមសុរិយា ស្រុកត្រាំកក់ ខេត្តតាកែវ។ គាត់មានបទពិសោធន៍ក្នុងការទាក់ទាញត្រីធម្មជាតិតាមបច្ចេកទេសថ្មី។ ស្រះរបស់គាត់មានទំហំ ២៣៤ ម៉ែត្រការេ និងជំរៅ ១.៥ ម៉ែត្រ។ កន្លងមកការទាក់ទាញត្រីធម្មជាតិតាមទំលាប់គាត់បានទទួលផលត្រី ៧០ គីឡូក្រាមប៉ុណ្ណោះ តែក្រោយពីបានអនុវត្តនូវគំនិតថ្មី គាត់ទទួលផលត្រីបានជាង ១២០ គីឡូក្រាម។ បទពិសោធន៍ដែលទទួលផលបានខ្ពស់របស់គាត់ បង្ហាញជូនដូចខាងក្រោម :

**ក. ការរៀបចំស្រះ**

- កាត់មែកឈើជុំវិញមាត់ស្រះ
- បើករង្វះទឹក ៤ ច្រក ដោយភ្ជាប់ពីប្រព័ន្ធប្រឡាយក្នុងស្រែមកចូលស្រះ
- ដាក់គល់ឈើបាតស្រះ ដូចជា មែក និងគល់អំពិលទឹក គល់ត្នោត (ទំហំសំរាស់ដាក់បាតស្រះ ៥ ម៉ែត្រការេ)
- ដាំកំប្លោកអោយដុះរុំចុងឬស្សីធ្វើជាស៊ុមដោតកណ្តាលស្រះ (ទំហំជំរកលើផ្ទៃស្រះ ៦ ម៉ែត្រការេ) ។

**ខ. ការផ្តល់ចំណី**

- ចំណីដែលផ្តល់អោយត្រីស៊ីមានដូចជា កន្ទក់ កណ្តៀរ អង្កង ដើមចេកហាន់បុកលាយកន្ទក់ សំណល់ផ្ទះបាយ
- ដើមចេកហាន់បុកលាយកន្ទក់ ០.៥ - ១ គីឡូក្រាម ក្នុង ១ ថ្ងៃ ចែកជា ២ ពេល (ព្រឹក និងល្ងាច) ។

**គ. ការគ្រប់គ្រង និងថែទាំ**

- រក្សាកំប្លោកមិនអោយដុះលើសពីរង្វង់ស៊ុមដែលដោតនៅកណ្តាលស្រះ
- ស្រះរបស់គាត់មានម្លប់ស្វាយគ្របពីលើផ្ទៃស្រះប្រហែលជា ២០ ភាគរយ
- ការពារមនុស្សឆក់ និងបង់សំណាញ់
- ផ្តល់ចំណីពី ៣ - ៥ ថ្ងៃក្នុង ១ អាទិត្យ
- រក្សាទឹកបានពេញ ១ ឆ្នាំ
- ទុកពូជត្រីគ្រប់ប្រភេទសរុប ៦ គីឡូក្រាម

**ឃ. យោបល់បន្ថែម**

- គួរបាចកំបោរសពី ៣ - ៥ គ.ក្រ ក្នុងផ្ទៃស្រះទំហំ ១០០ ម៉ែត្រការេ
- គួរស្តារស្រះអោយបានជ្រៅពី ២ - ៣ ម៉ែត្រ ។

## ៥.៤ បទពិសោធន៍កសិករ ហម ត្រឹក

បងប្រុស ហម ត្រឹក ជាកសិករនៅភូមិទ្រា ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង។ គាត់មានបទពិសោធន៍ក្នុងការទាក់ទាញត្រីធម្មជាតិតាមបច្ចេកទេសថ្មី។ ស្រះរបស់គាត់មានទំហំ ១០០ ម៉ែត្រការេ ជំរៅ ១,៥ ម៉ែត្រ និងបៀវមានទំហំ ១២០ ម៉ែត្រការេ ជំរៅ ២,៥ ម៉ែត្រ។ កន្លងមកការទាក់ទាញត្រីធម្មជាតិតាមទំលាប់គាត់បានទទួលផលត្រី ៦០ គីឡូក្រាមប៉ុណ្ណោះ តែក្រោយពីបានអនុវត្តនូវគំនិតថ្មី គាត់ទទួលផលត្រីបានជាង ១៥០ គីឡូក្រាម ។ បទពិសោធន៍ដែលទទួលផលបានខ្ពស់របស់គាត់ បង្ហាញជូនដូចខាងក្រោម :

**ក. ការរៀបចំស្រះ**

- ស្តារភក់បាតស្រះ និងបៀវ
- ប្រើកំបោរសរអស់ ២០ គីឡូក្រាម
- បើករង្វះទឹក ២ ច្រក ដោយភ្ជាប់ពីប្រព័ន្ធប្រឡាយក្នុងស្រែមកចូលស្រះ
- ដាក់គល់ឈើនៅបាតស្រះ (ទំហំសំរាស់ដាក់បាតស្រះ ៣ ម៉ែត្រការេ)
- ដាំកំប្លោកអោយដុះ រុំចុងឬស្សីធ្វើជាស៊ុមដោតកណ្តាលស្រះ (ទំហំជំរកលើផ្ទៃស្រះ ៥ ម៉ែត្រការេ) ។

**ខ. បង្កើតចំណីធម្មជាតិ**

- ដាក់លាមកគោ ១០០ គីឡូក្រាម
- ទន្រ្ទានខែត្រ ១៥០ គីឡូក្រាម ។

**គ. ការផ្តល់ចំណី**

- ចំណីដែលផ្តល់អោយត្រីស៊ីមានដូចជា ចកបាយទា កន្ទក់ កណ្តៀរ
- កន្ទក់ ៥ ថ្ងៃអោយម្តង ( ១ ដង អោយស៊ី ០,៥០ គីឡូក្រាម)
- ចកបាយទា កណ្តៀរ (តាមពេលរកបាន) ។

**ឃ. ការគ្រប់គ្រង និងថែទាំ**

- រក្សាកំប្លោកមិនអោយដុះលើសពីរង្វង់ស៊ុមដែលដោតនៅកណ្តាលស្រះ
- ការពារមនុស្សឆក់ និងបង់សំណាញ់
- រក្សាទឹកបានពេញ ១ ឆ្នាំ
- ទុកពូជត្រីគ្រប់ប្រភេទសរុប ៥ គីឡូក្រាម ។

**ង. យោបល់បន្ថែម**

- គួរបាចកំបោរសពី ៣ - ៥ គ.ក្រ ក្នុងផ្ទៃស្រះទំហំ ១០០ ម៉ែត្រការេ
- ផ្តល់ចំណី ៣ - ៥ ថ្ងៃក្នុង ១ អាទិត្យ ។

## ៥.៥ បទពិសោធន៍កសិករ ឈឹម សាមឿន

បងប្រុស ឈឹម សាមឿន ជាកសិករនៅភូមិអង្គាញ់ ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង។ គាត់មានបទពិសោធន៍ក្នុងការទាក់ទាញត្រីធម្មជាតិតាមបច្ចេកទេសថ្មី។ ស្រះរបស់គាត់មានទំហំ ១២០ ម៉ែត្រការេ និងជំរៅ ២ ម៉ែត្រ។ កន្លងមកការទាក់ទាញត្រីធម្មជាតិតាមទំលាប់គាត់បានទទួលផលត្រី ៤០ គីឡូក្រាមប៉ុណ្ណោះ តែក្រោយពីបានអនុវត្តនូវគំនិតថ្មីគាត់ទទួលផលត្រីបានជាង ៦០ គីឡូក្រាម។ បទពិសោធន៍ដែលទទួលផលបានខ្ពស់របស់គាត់ បង្ហាញជូនដូចខាងក្រោម :

### ក. ការរៀបចំស្រះ

- ស្តារភក់បាតស្រះ និងកាត់មែកឈើជុំវិញមាត់ស្រះ
- បាចកំបោរស ៦ គីឡូក្រាម
- បើករង្វះទឹក ៣ ច្រក ដោយភ្ជាប់ពីប្រព័ន្ធប្រឡាយក្នុងស្រែមកចូលស្រះ
- ដាក់គល់ឈើបាតស្រះ (ទំហំសំរាស់ដាក់បាតស្រះ ១ ម៉ែត្រការេ)
- ដាំកំប្លោកអោយដុះរុំចុងឬស្សីធ្វើជាស៊ុមដោតកណ្តាលស្រះ (ទំហំជំរកលើផ្ទៃស្រះ ៣ ម៉ែត្រការេ)។

### ខ. បង្កើតចំណីធម្មជាតិ

- ដាក់លាមកគោ ៥០ គីឡូក្រាម
- ទន្រ្ទានខែត្រ ៤០ គីឡូក្រាម ។

### គ. ការផ្តល់ចំណី

- ចំណីដែលផ្តល់អោយត្រីស៊ីមានដូចជា កាកសំណល់ផ្ទះបាយ ចកបាយទា លាមកជ្រូក
- ផ្តល់ចំណី ៥ ថ្ងៃអោយម្តង ( ១ ដង អោយស៊ី 0,៥0 គីឡូក្រាម) ។

### ឃ. ការគ្រប់គ្រង និងថែទាំ

- រក្សាកំប្លោកមិនអោយដុះលើសពីរង្វង់ស៊ុមដែលដោតនៅកណ្តាលស្រះ
- ការពារមនុស្សឆក់ និងបង់សំណាញ់
- រក្សាទឹកបានពេញ ១ ឆ្នាំ
- ទុកពូជត្រីគ្រប់ប្រភេទសរុប ៣ គីឡូក្រាម ។

### ង. យោបល់បន្ថែម

- គួរដាក់គល់ឈើនៅបាតស្រះពី ៣ - ៤ ម៉ែត្រការេ
- ដាក់អាចម៍គោបន្ថែម ។

## ៦. ការសរុបនូវចំណុចសំខាន់ៗក្នុងការទាក់ទាញត្រីធម្មជាតិបានផលខ្ពស់

សរុបមកដើម្បីអោយយើងទាក់ទាញត្រីធម្មជាតិបានផលខ្ពស់ លោកអ្នកគួរអនុវត្តន៍តាមចំណុចសំខាន់ដូចខាងក្រោម :

- ☞ រៀបចំសំអាតស្រះ និងបៀរ ដោយប្រើកំបោរស, ហាលបាតស្រះ និងដាក់ជីលាមកសត្វ
- ☞ ស្តារបាតស្រះ បៀរ អោយបានជ្រៅពី ២ - ៣ម និង ប្រឡាយជំរៅ ០,៥០ - ១ ម ។
- ☞ ធ្វើជំរកអោយត្រី ( ជំរកផ្ទៃលើ និង ផ្ទៃបាត)
- ☞ បើករង្វះទឹកចូលស្រះ ឬ បៀរ ពី ២ - ៣ ច្រក
- ☞ ទុកត្រីមេពូជ ៣ - ៥ គ.ក្រ ក្នុង ១ គ្រួសារ និង រក្សាពូជត្រីល្អិតកុំអោយដាច់ពូជ
- ☞ រក្សាប្រភេទត្រីល្អិតៗ និងមេពូជដែលស្គាល់ជំរក
- ☞ ផ្តល់កន្ទក់អោយប្រភេទត្រីតូចមករស់នៅច្រើន ដើម្បីជាចំណីត្រីធំ
- ☞ បង្កើនគុណភាពទឹក និងចំណីធម្មជាតិ ដោយថែមជីកំប៉ុស្ត និងទន្ទ្រានខែគ្របន្ថែមរៀងរាល់ខែ
- ☞ ប្រមូលកូនត្រីតាមវាលស្រែដែលដាច់ទឹក ( គោក) យកមកលែងក្នុងជំរក ( ស្រះ, បៀរ,...)
- ☞ ផ្តល់ចំណីអោយបានទៀងទាត់ ( ព្រឹក ឬ ល្ងាច) ។

ដូចគ្នាដែរដើម្បីទាក់ទាញត្រីធម្មជាតិបានច្រើន អ្នកគួរជៀសវាងនូវចំណុចមួយចំនួនដូចខាងក្រោម :

- ☞ កុំបិទច្រកផ្លូវត្រី ( រង្វះ) ចូលស្រះ បៀរ ប្រឡាយ
- ☞ កុំប្រើថ្នាំពុល ជីគីមី ឧបករណ៍ឆក់ក្នុងការចាប់ត្រី
- ☞ ការបូមផ្តាច់ពូជត្រី, រើជំរកត្រីមុនពេលប្រមូលផល
- ☞ ការចាប់ត្រីកូន និងត្រីមេពូជហួប
- ☞ ការដាំល្ហុក និងបង្ហូរសារធាតុពុល
- ☞ ត្រាំឈើ ឬ ស្លឹកប្រក់ផ្ទះ
- ☞ មែកឈើម្លប់ផ្ទះ និងជ្រុះស្លឹក
- ☞ កុំប្រមូលផលត្រី ហើយបាចទឹកមកលើដីអស់សំណើម ធ្វើឱ្យកូនត្រីល្អិតៗងាប់
- ☞ កុំដាំប្រភេទឈើដែលមានស្លឹក ឬ ឫសជ្រុះ ឬ ចាក់ចូលក្នុងស្រះធ្វើអោយប៉ះពាល់ដល់ត្រី ( ទឹកស្អុយត្រីពុល និង ងាប់) ។

## ឧបសម្ព័ន្ធ

យើងត្រូវកត់ត្រារៀងរាល់ការចំណាយរហូតដល់ពេលប្រមូលផលត្រី:

តារាង ១ ការកត់ត្រាការចំណាយលើមុខផ្សេងៗ

| ល.រ | មុខចំណាយ | ឯកតា | បរិមាណ | តំលៃរាយ (រៀល) | តំលៃសរុប (រៀល) |
|---|---|---|---|---|---|
| ១ | ត្រីមេពូជ | គ.ក្រ | ? | ? | ? |
| ២ | ប្រេងឥន្ធនៈ (បូមទឹក) | លីត្រ | ? | ? | ? |
| ៣ | ចំណី | គ.ក្រ | ? | ? | ? |
| ៤ | ជី (លាមកសត្វ និង រុក្ខជាតិ) | គ.ក្រ | ? | ? | ? |
| ៥ | កំបោរស | គ.ក្រ | ? | ? | ? |
| ៦ | កំលាំងពលកម្ម (ឈ្នួល) | នាក់ | ? | ? | ? |
| ៧ | ចំណាយផ្សេងៗ | | ? | ? | ? |
| សរុប | | | | | ? |

តារាង ២ ការកត់ត្រាការប្រមូលផលត្រី

| ស្រះ, បៀរ និង ប្រឡាយ | ទំហំជំរកត្រី (ម$^{២}$) | បរិមាណត្រីមេពូជ | | ទំងន់ត្រីប្រមូលផល | | តំលៃត្រី | |
|---|---|---|---|---|---|---|---|
| | | ប្រភេទត្រី | ចំនួនក្បាល | ក្បាល/គ.ក្រ | ទំងន់សរុប ( គ.ក្រ ) | តំលៃរាយ/គ.ក្រ | តំលៃសរុប |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

# ឯកសារយោង


១. Dela Cruz, C.R., et all. (1992). Rice-Fish Research and Development in Asia ការសិក្សាស្រាវជ្រាវត្រី-ស្រូវ និងការអភិវឌ្ឍន៍នៅអាស៊ី. Page: 77 - 89.

២. Duy Khoa . (1994). ការការពារ និងព្យាបាលជំងឺត្រីទឹកសាប ( ភាសាវៀតណាម ).

៣. FAO Training Series 24. (1994). Handbook on Small-Scale Freshwater Fish Farming. សៀវភៅខ្នាតតូច: ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ.

៤. FAO (2001). Integrated Agriculture-Aquaculture. Fisheries Technical Paper, Rome, No.407.

៥. Mai Dinh Yen. (1978). ការចំណាត់ថ្នាក់ត្រីទឹកសាប ( ភាសាវៀតណាម ).

៦. Tran Van Ky. (1995). ចំណើធម្មជាតិរបស់ត្រី ( ភាសាវៀតណាម ).

៧. Waltter J. Rainboth (1996). Fishes of the Cambodian Mekong, Rome, England. ត្រីទឹកសាបនៅទន្លេមេគង្គកម្ពុជា.

៨. Woynaronvich, E. & Horvath, L. (1980). The Artificial Propagation of Warm-Water Finfishes - A manual for extension. FAO Fisheries Technical បច្ចេកទេសផលិតពូជត្រីសិប្បនិម្មិត សំរាប់ការផ្សព្វផ្សាយ. Paper No.201.

៩. រាជ សុភាព (២០០២). បច្ចេកទេសចិញ្ចឹម និងថែបំប៉នត្រីមេពូជ (ឯកសារមិនទាន់បោះពុម្ពផ្សាយជាផ្លូវការ) ។

## មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក/CEDAC)

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ឯករាជ្យ មិនស្វែងរកកំរៃផលប្រយោជន៍បុគ្គល និងមិនពាក់ព័ន្ធគណបក្សនយោបាយ ។ "សេដាក" ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៧ ក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍន៍សង្គមកម្ពុជាមួយប្រកបដោយចីរភាព និងសមធម៌ ដែលប្រជាកសិករ និងអ្នកបរិភោគមានជីវិតរស់នៅប្រកបដោយភាពសប្បាយរីករាយ ។

សេដាក បានចាប់ដៃជាមួយកសិករ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីផ្តួចផ្តើមគំនិតអនុវត្ត និងគាំទ្រដល់គំរោង ឬសកម្មភាពដែលចូលរួមចំណែកដល់អធិបតេយ្យភាពស្បៀង និងការបង្កើននូវគុណភាពនៃជីវិតរបស់ប្រជាកសិករ និងអ្នកបរិភោគ ដោយជាមួយគ្នានោះរក្សា និងបង្កើននូវគុណភាពនៃធនធាន ធម្មជាតិ និងការសហការគ្នាក្នុងសង្គម ។

☞ *ចងក្រង និងបោះពុម្ពផ្សាយដោយ **មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា** (សេដាក/CEDAC)*

☞ *ឧបត្ថម្ភថវិកាដោយអង្គការអុកស្វាមអាមេរិក (Oxfam America)*

☞ *ពត៌មានផ្សេងៗ និង ការបែងចែកផ្សព្វផ្សាយ សូមទំនាក់ទំនង:*

*ផ្ទះលេខ ៣៩ ផ្លូវលេខ ៥២៨ សង្កាត់បឹងកក់ ១ ខ័ណ្ឌទួលគោក*

*ប្រអប់សំបុត្រលេខ ១១១៨ រាជធានីភ្នំពេញ*

*ទូរស័ព្ទ: (០២៣) ៨៨០ ៩១៦ ទូរសារ: (០២៣) ៨៨៥ ១៤៦ E.mail : Cedac@camnet.com.kh*



ការស្តារស្រះ



ស្រះត្រីកន្លងរបងតាមធម្មជាតិ



ស៊ុំស្តុកត្រីមេពូជទុកលែងចូលស្រះវិញ



ការលែងត្រីមេពូជចូលស្រះវិញ



ប្រព័ន្ធប្រឡាយក្នុងរ៉ុស



ផលត្រីដែលប្រមូលបាន